# មេត្តសូត្រ (អធិប្បាយធមិករណី)

# (ដកពីបិដក និង អដ្ឋកថា)




ដកស្រង់រៀបរៀងដោយភិក្ខុ សារត្ថធម្មោ នួន សារ៉ែត ព.ស២៥៦៦, គ.ស២០២៣

# សេចក្តីផ្តើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ ទួន សារ៉េត បាន រៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និង បដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជា និស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹង ឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្តីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយ ព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្តីសុខ សេចក្តីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី០៦ ខែមេសាឆ្នាំ២០២៣

# មេត្តសុត្តំ

ករណីយមត្ថកុសលេន, យន្ត សន្តំ បទំ អភិសមេច្ច;

សក្កោ ឧជូ ច សុហុជូ  ច, សុវចោ ចស្ស មុទុ អនតិមានី។

សន្តុស្សកោ ច សុភរោ ច, អប្បកិច្ចោ ច សល្លហុកវុត្តិ;

សន្តិន្ទ្រិយោ ច និបកោ ច, អប្បគព្ភោ កុលេស្វននុគិទ្ធោ។

ច ខុទ្ទមាចរេ កិញ្ចិ, យេន វិញ្ញូ បរេ ឧបវទេយ្យុំ;

សុខិនោ វ ខេមិនោ ហោន្តុ, សព្វសត្តា  ភវន្តុ សុខិតត្តា។

យេ កេចិ ឃាណភូតត្ថិ, តសា វា ថាវរា វនវសេសា;

ទីឃា វា យេ វ មហន្តា , មជ្ឈិមា រស្សកា អណុកថូលា។

ទិដ្ឋា វា យេ វ អទិដ្ឋា , យេ វ  ទូរេ វសន្តិ អវិទូរេ;

ភូតា វ សម្ភវេសី វ , សព្វសត្តា ភវន្តុ សុខិតត្តា។

ន បរោ បរំ និកុព្វេថ, នាតិមញ្ញេថ កត្ថចិ ន កញ្ចិ ;

ព្យារោសនា បដិយសញ្ញា, នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ។

មាតា យថា និយំ បុត្តមាយុសា   ឯកបុត្តមនុរក្ខេ;

ឯវម្បិ សព្វភូតេសុ, មានសំ ភាវយេ អបរិមាណំ។

មេត្តញ្ច សព្វលោកស្មិ, មានសំ ភាវយេ អបរិមាណំ;

ឧទ្ធំ អធោ ច តិរិយញ្ច, អសម្ពាធំ អវេរមសបត្តំ។

តិដ្ឋំ ចរំ និសិន្នោ វ , សយានោ យាវតាស្ស វិគតមិទ្ធោ ;

ឯតំ សតឹ អធិដ្ឋេយ្យ, ព្រហ្មមេតំ វិហារមិធមាហុ។

**ទិដ្ឋិញ្ច អនុបគ្គម្ម, សីលវា ទស្សនេន សម្បន្នោ;**

**កាមេសុ វិនយ គេធំ, ន ហិ ជាតុគ្គព្ភសេយ្យ បុនរេតីតិ៕**

## មេត្តសូត្រ

[១៥] កិច្ចណា ដែលអរិយបុគ្គល បានត្រាស់ដឹងនូវចំណែកនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្រអ្នកឈ្លាសក្នុងប្រយោជន៍ គួរធ្វើ (កុលបុត្រនោះ) គួរជាអ្នកអាចហ៊ានផង មានកាយវាចាត្រង់ផង មានចិត្តត្រង់ល្អផង ជាបុគ្គលប្រដៅងាយផង មានសភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង។ ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង មិនមានកិច្ចកង្វល់ផង ប្រព្រឹត្តស្រាលព្រមផង មានឥន្ទ្រិយស្ងប់ផង មានប្រាជ្ញាចាស់ផង មិនថ្កុំថ្កើងផង មិនជាប់ចំពាក់ក្នុងត្រកូលទាំងឡាយផង។ វិញ្ញូជនទាំងឡាយ គប្បីតិះដៀលនូវជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច (ហើយគប្បីផ្សាយមេត្តាចិត្ត ចំពោះពួកសត្វថា) សូមឲ្យពួកសត្វទាំងពួង មានសេចក្ដីសុខ មានសេចក្ដីក្សេមក្សាន្ត មានខ្លួនដល់នូវសេចក្ដីសុខចុះ ពួកសត្វដែលមានជីវិត ឥតមានសេសសល់ ទោះសត្វជាអ្នកមានសេចក្ដីតក់ស្លុត គឺនៅមានតណ្ហាក្ដី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្ដី ពួកសត្វដែលមានកាយវែងក្ដី ធំក្ដី មានកាយយ៉ាងកណ្ដាលក្ដី ខ្លីក្ដី ស្គមក្ដី ធាត់ក្ដី ពួកសត្វដែលយើងឃើញក្ដី មិនឃើញក្ដី ពួកសត្វដែលនៅក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី កើតរួចហើយក្ដី កំពុងស្វែងរកកំណើតក្ដី សូមឲ្យសត្វទាំងអស់ (នោះ) មានខ្លួនដល់នូវសេចក្ដីសុខចុះ។ សត្វដទៃ មិនគួរកំហែងបៀតបៀនសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួច ក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្ដីទុក្ខ ដល់គ្នានឹងគ្នាដោយសេចក្ដីក្រេវក្រោធ ដោយសេចក្ដីចង្អៀតចង្អល់ចិត្តឡើយ។ មាតាថ្នមរក្សាបុត្ត ដែលកើតអំពីខ្លួន ជាបុត្តតែមួយ ដោយអាយុ គឺថាសូម្បីជីវិតក៏ហ៊ានលះបង់ ក្នុងការរក្សានូវបុត្តបាន យ៉ាងណាមិញ បុគ្គលគួរចំរើនមេត្តា

ចិត្ត មិនមានប្រមាណ ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង បុគ្គលគួរចំរើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ ទាំងខាងលើ ខាងក្រោម ទាំងទទឹង គឺត្រង់កណ្តាលផង (បុគ្គលអ្នកចំរើនមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់ អស់កាលត្រឹមណា គួរដំកល់នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមណោះ)។ បណ្ឌិតទាំងឡាយ ពោលនូវដំណើរនុ៎ះ ថាជាព្រហ្មវិហារ ក្នុងសាសនានេះ។ (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិន អាស្រ័យនូវទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយ ដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ រមែងមិនមកកាន់គព្ភសេយ្យាសន៍ គឺថា មិនមកកើតក្នុងគភ៌ទៀតឡើយ។

ចប់ មេត្តសូត្រ ទី៨។

## ៩.មេត្តសុត្តវណ្ណនា (អដ្ឋកថា)

## និក្ខេបប្បយោជនំ

ឥទានិ និធិកណ្ឌានន្តរំ និក្ខិត្តស្ស មេត្តសុត្តស្ស វណ្ណនាក្កមោ អនុប្បត្តោ។ តស្ស ឥធ និក្ខេបប្បយោជនំ វត្វា តតោ បរំ

"យេន វុត្តំ យទា យត្ថ, យស្មា ចេតេស ទីបនា;
និទានំ សោធយិត្វាស្ស, ករិស្សាមត្ថវណ្ណនំ"។

តត្ថ យស្មា និធិកណ្ឌេន ទានសីលាទិបុញ្ញសម្បទា វុត្តា, សា ច សត្តេសុ មេត្តាយ ក តាយ មហប្ផលា ហោតិ យាវ ពុទ្ធភូមឹ បាបេតុំ សមត្ថា, តស្មា តស្សា បុញ្ញសម្បទាយ

ឧបការទស្សនត្ថំ, យស្មា វា សរណេហិ សាសនេ ឱតរិត្វា សិក្ខាបទេហិ សីលេ បតិដ្ឋិតានំ ទ្វត្តឹសាការេន រាគប្បហានសមត្ថំ, កុមារបញ្ហេន មោហប្បហានសមត្ថញ្ច កម្មដ្ឋានំ ទស្សេត្វា, មង្គលសុត្តេន តស្ស បវត្តិយា មង្គលភាវោ អត្តរក្ខា ច, រតនសុត្តេន តស្សានុរូបា បររក្ខា, តិរោកុឌ្ឌេន រតនសុត្តេ វុត្តភូតេសុ ឯកច្ចភូតទស្សនំ វុត្តប្បការាយ បុញ្ញសម្បត្តិយា បមជ្ជន្តានំ វិបត្តិ ច, និធិកណ្ឌេន តិរោកុឌ្ឌេ វុត្តវិបត្តិបដិបក្ខភូតា សម្បត្តិ ច ទស្សិតា, ទោសប្បហានសមត្ថំ បន កម្មដ្ឋានំ អទស្សិតមេវ, តស្មា តំ ទោសប្បហានសមត្ថំ កម្មដ្ឋានំ ទស្សេតុំ ឥទំ មេត្តសុត្តំ ឥធ និក្ខិត្តំ។ ឯវញ្ហិ សុបរិបូរោ ហោតិ ខុទ្ទកបាឋោតិ ឥទមស្ស ឥធ និក្ខេបប្បយោជនំ។

## និទានសោធនំ

ឥទានិ យាយំ

"យេន វុត្តំ យទា យត្ថ, យស្មា ចេតេស ទីបនា;
និទានំ សោធយិត្វាស្ស, ករិស្សាមត្ថវណ្ណន"ន្តិ។

មាតិកា និក្ខិត្តា, តត្ថ ឥទំ មេត្តសុត្តំ ភគវតាវ វុត្តំ, ន សាវកាទីហិ, តញ្ច បន យទា ហិមវន្តបស្សតោ ទេវតាហិ ឧព្វាឡ្ហា ភិក្ខូ ភគវតោ សន្តិកំ អាគតា, តទា សាវត្ថិយំ តេសំ ភិក្ខូនំ បរិត្តត្ថាយ កម្មដ្ឋានត្ថាយ ច វុត្តន្តិ ឯវំ តាវ សង្ខេបតោ ឯតេសំ បទានំ ទីបនា និទានសោធនា វេទិតព្វា។

វិត្ថារតោ បន ឯវំ វេទិតព្វា ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ឧបកដ្ឋាយ វស្សូបនាយិកាយ, តេន ខោ បន សមយេន សម្ពហុលា នានាវេរជ្ជកា ភិក្ខូ ភគវតោ សន្តិកេ កម្មដ្ឋានំ គហេត្វា តត្ថ តត្ថ វស្សំ ឧបគន្តុកាមា ភគវន្តំ ឧបសង្កមន្តិ។ តត្រ សុទំ ភគវា រាគចរិតានំ សវិញ្ញាណកអវិញ្ញាណកវសេន ឯកាទសវិធំ អសុភកម្មដ្ឋានំ, ទោសចរិតានំ ចតុព្វិធំ មេត្តាទិកម្មដ្ឋានំ, មោហចរិតានំ មរណស្សតិកម្មដ្ឋានាទីនិ, វិតក្កចរិតានំ

អានាបានស្សតិបឋវីកសិណាទីនិ, សទ្ធាចរិតានំ ពុទ្ធានុស្សតិកម្មដ្ឋានាទីនិ, ពុទ្ធិចរិតានំ ចតុធាតុវវត្ថានាទីនីតិ ឥមិនា នយេន ចតុរាសីតិសហស្សប្បភេទចរិតានុ- កូលានិ កម្មដ្ឋានានិ កថេតិ។

អថ ខោ បញ្ចមត្តានិ ភិក្ខុសតានិ ភគវតោ សន្តិកេ កម្មដ្ឋានំ ឧគ្គហេត្វា សប្បាយសេនាសនញ្ច គោចរគាមញ្ច បរិយេសមានានិ អនុបុព្ពេន គន្ត្វា បច្ចន្តេ ហិមវន្តេន សទ្ធឹ ឯកាពទ្ធំ នីលកាចមណិសន្និភសិលាតលំ សីតលឃនច្ឆាយនីលវនសណ្ឌមណ្ឌិតំ មុត្តាជាលរជតបដ្ដសទិសវាលុកាកិណ្ណភូមិភាគំ សុចិសាតសីតលជលាសយបរិវារិតំ បព្វតមទ្ទសំសុ។ អថ តេ ភិក្ខូ តត្ថេករត្តឹ វសិត្វា បភាតាយ រត្តិយា សរីរបរិកម្មំ កត្វា តស្ស អវិទូរេ អញ្ញតរំ គាមំ បិណ្ឌាយ បវិសឹសុ។ គាមោ ឃននិវេសនសន្និវិដ្ឋកុលសហស្សយុត្តោ, មនុស្សា ចេត្ថ សទ្ធា បសន្នា តេ បច្ចន្តេ បព្វជិតទស្សនស្ស ទុល្លភតាយ ភិក្ខូ ទិស្វា ឯវ បីតិសោមនស្សជាតា ហុត្វា តេ ភិក្ខូ ភោជេត្វា "ឥធេវ, ភន្តេ, តេមាសំ វសថា"តិ យាចិត្វា បញ្ច បធានកុដិសតានិ ការេត្វា តត្ថ មញ្ចបីឋបានីយបរិភោជនីយឃដាទីនិ សព្វូបករណានិ បដិយាទេសុំ។

ភិក្ខូ ទុតិយទិវសេ អញ្ញំ គាមំ បិណ្ឌាយ បវិសឹសុ។ តត្ថបិ មនុស្សា តថេវ ឧបដ្ឋហិត្វា វស្សាវាសំ យាចឹសុ។ ភិក្ខូ "អសតិ អន្តរាយេ"តិ អធិវាសេត្វា តំ វនសណ្ឌំ បវិសិត្វា សព្វរត្តិន្ទិវំ អារទ្ធវីរិយា យាមឃណ្ឌិកំ កោដ្ដេត្វា យោនិសោមនសិការពហុលា វិហរន្តា រុក្ខមូលានិ ឧបគន្ត្វា និសីទឹសុ។ សីលវន្តានំ ភិក្ខូនំ តេជេន វិហតតេជា រុក្ខទេវតា អត្តនោ អត្តនោ វិមានា ឱរុយ្ហ ទារកេ គហេត្វា ឥតោ ចិតោ វិចរន្តិ។ សេយ្យថាបិ នាម រាជូហិ វា រាជមហាមត្តេហិ វា គាមកាវាសំ គតេហិ គាមវាសីនំ ឃរេសុ ឱកាសេ គហិតេ ឃរមនុស្សា ឃរា និក្ខមិត្វា អញ្ញត្រ វសន្តា "កទា នុ គមិស្សន្តី"តិ ទូរតោវ ឱលោកេន្តិ, ឯវមេវ ទេវតា អត្តនោ អត្តនោ វិមានានិ ឆឌ្ឌេត្វា ឥតោ ចិតោ ច វិចរន្តិយោ ទូរតោវ ឱលោកេន្តិ "កទា នុ ភទ

ន្តា គមិស្សន្តី”តិ។ តតោ ឯវំ សមចិន្តេសុំ “បឋមវស្សូបគតា ភិក្ខូ អវស្សំ តេមាសំ វសិស្សន្តិ, មយំ បន តាវ ចិរំ ទារកេ គហេត្វា ឱក្កម្ម វសិតុំ ន សក្កោម, ហន្ទ មយំ ភិក្ខូនំ ភយានកំ អារម្មណំ ទស្សេមា”តិ។ តា រត្តឹ ភិក្ខូនំ សមណធម្មករណ -វេលាយ ភីសនកានិ យក្ខរូបានិ និម្មិនិត្វា បុរតោ បុរតោ តិដ្ឋន្តិ, ភេរវសទ្ទញ្ច ករោន្តិ។ ភិក្ខូនំ តានិ រូបានិ ទិស្វា តញ្ច សទ្ទំ សុត្វា ហទយំ ផន្ទិ, ទុព្ពណ្ណា ច អហេសុំ ឧប្បណ្ឌុប្ប-ណ្ឌុកជាតា។ តេន តេ ភិក្ខូ ចិត្តំ ឯកគ្គំ កាតុំ នាសក្ខឹសុ, តេសំ អនេកគ្គចិត្តានំ ភយេន ច បុនប្បុនំ សំវិគ្គានំ សតិ សម្មុស្សិ, តតោ តេ សំមុដ្ឋសតីនំ ទុគ្គន្ធានិ អារម្មណានិ បយោជេ-សុំ, តេសំ តេន ទុគ្គន្ធេន និម្មថិយមានមិវ មត្ថលុង្គំ អហោសិ, គាឡ្ហា សីសវេទនា ឧប្បជ្ជឹ-សុ, ន ច តំ បវត្តឹ អញ្ញមញ្ញស្ស អារោចេសុំ។

អថេកទិវសំ សង្ឃត្ថេរស្ស ឧបដ្ឋានកាលេ សព្វេសុ សន្និបតិតេសុ សង្ឃត្ថេរោ បុច្ឆិ “តុម្ហាកំ, អាវុសោ, ឥមំ វនសណ្ឌំ បវិដ្ឋានំ កតិបាហំ អតិវិយ បរិសុទ្ធោ ឆវិវណ្ណោ អហោសិ បរិយោទាតោ, វិប្បសន្នានិ ច ឥន្ទ្រិយានិ, ឯតរហិ បនត្ថ កិសា ទុព្ពណ្ណា ឧប្បណ្ឌុប្បណ្ឌុក-ជាតា, កឹ វោ ឥធ អសប្បាយ”ន្តិ។ តតោ ឯកោ ភិក្ខុ អាហ “អហំ, ភន្តេ, រត្តឹ ឦទិសញ្ច ឦទិសញ្ច ភេរវារម្មណំ បស្សាមិ ច សុណាមិ ច, ឦទិសញ្ច គន្ធំ ឃាយាមិ, តេន មេ ចិត្តំ ន សមាធិយតី”តិ, ឯតេនេវ ឧបាយេន សព្វេវ តេ តំ បវត្តឹ អារោចេសុំ។ សង្ឃត្ថេរោ អាហ “ភគវតា, អាវុសោ, ទ្វេ វស្សូបនាយិកា បញ្ញត្តា, អម្ហាកញ្ច ឥទំ សេនាសនំ អសប្បាយំ, អាយាមាវុសោ, ភគវតោ សន្តិកំ គន្ត្វា អញ្ញំ សប្បាយសេនាសនំ បុច្ឆាមា”តិ។ “សាធុ, ភន្តេ”តិ តេ ភិក្ខូ ថេរស្ស បដិស្សុណិត្វា សព្វេវ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ អនុបលិត្តត្តា កុលេសុ កញ្ចិ អនាមន្តេត្វា ឯវ យេន សាវត្ថិ តេន ចារិកំ បក្កមឹសុ។ អនុបុព្វេន សាវត្ថឹ គន្ត្វា ភគវតោ សន្តិកំ អាគមឹសុ។

ភគវា តេ ភិក្ខូ ទិស្វា ឯតទវោច “ន, ភិក្ខវេ, អន្តោវស្សំ ចារិកា ចរិតព្វាតិ មយា សិក្ខាបទំ បញ្ញត្តំ, កិស្ស តុម្ហេ ចារិកំ ចរថា”តិ។ តេ ភគវតោ សព្វមារោចេសុំ ភគវា អាវជ្ជេន្តោ

សកលជម្ពុទីបេ អន្តមសោ ចតុបាទបីឋកដ្ឋានមត្តម្បិ តេសំ សប្បាយសេនា-សនំ នាទ្ទសុ។ អថ តេ ភិក្ខូ អាហ "ន, ភិក្ខវេ, តុម្ហាកំ អញ្ញំ សប្បាយសេនាសនំ អត្ថិ, តត្ថេវ តុម្ហេ វិហរន្តា អាសវក្ខយំ បាបុណិស្សថ, គច្ឆថ, ភិក្ខវេ, តមេវ សេនាសនំ ឧបនិស្សាយ វិហរថ, សចេ បន ទេវតាហិ អភយំ ឥច្ឆថ, ឥមំ បរិត្តំ ឧគ្គណ្ហថ។ ឯតញ្ហិ វោ បរិត្តញ្ច កម្មដ្ឋានញ្ច ភវិស្សតី"តិ ឥទំ សុត្តមភាសិ។

អបរេ បនាហុ "គច្ឆថ, ភិក្ខវេ, តមេវ សេនាសនំ ឧបនិស្សាយ វិហរថា"តិ ឥទញ្ច វត្វា ភគវា អាហ "អបិច ខោ អារញ្ញកេន បរិហរណំ ញាតព្វំ។ សេយ្យថិទំ សាយំ បាតំ ករណវសេន ទ្វេ មេត្តា ទ្វេ បរិត្តា ទ្វេ អសុភា ទ្វេ មរណស្សតី អដ្ឋមហាសំវេគវត្ថុសមាវ-ជ្ជនញ្ច, អដ្ឋ មហាសំវេគវត្ថូនិ នាម ជាតិជរាព្យាធិមរណំ ចត្តារិ អបាយទុក្ខានីតិ, អថ វា ជាតិជរាព្យាធិមរណានិ ចត្តារិ, អបាយទុក្ខំ បញ្ចមំ, អតីតេ វដ្ដមូលកំ ទុក្ខំ, អនាគតេ វដ្ដមូលកំ ទុក្ខំ, បច្ចុប្បន្នេ អាហារបរិយេដ្ឋិមូលកំ ទុក្ខ"ន្តិ។ ឯវំ ភគវា បរិហរណំ អាចិក្ខិត្វា តេសំ ភិក្ខូនំ មេត្តត្ថញ្ច បរិត្តត្ថញ្ច វិបស្សនាបាទកជ្ឈានត្ថញ្ច ឥទំ សុត្តមភាសីតិ។ ឯវំ វិត្ថារតោបិ "យេន វុត្តំ យទា យត្ថ, យស្មា ចេ"តិ ឯតេសំ បទានំ ទីបនា និទានសោធនា វេទិតព្វា។

ឯត្តាវតា ច យា សា "យេន វុត្តំ យទា យត្ថ, យស្មា ចេតេស ទីបនា។ និទានំ សោធយិត្វា"តិ មាតិកា ឋបិតា, សា សព្វាការេន វិត្ថារិតា ហោតិ។

## បឋមគាថាវណ្ណនា

១.ឥទានិ "អស្ស ករិស្សាមត្ថវណ្ណន"ន្តិ វុត្តត្តា ឯវំ កតនិទានសោធនស្ស អស្ស សុត្ត-ស្ស អត្ថវណ្ណនា អារព្ភតេ។ តត្ថ ករណីយមត្ថកុសលេនាតិ ឥមិស្សា បឋមគាថាយ តាវ អយំ បទវណ្ណនា ករណីយន្តិ កាតព្វំ, ករណារហន្តិ អត្ថោ។ អត្ថោតិ បដិបទា, យំ វា កិញ្ចិ អត្តនោ ហិតំ, តំ សព្វំ អរណីយតោ អត្ថោតិ វុច្ចតិ, អរណីយតោ នាម ឧបគន្តព្វតោ។ អត្ថេ កុសលេន អត្ថកុសលេន អត្ថឆេកេនាតិ វុត្តំ ហោតិ។ យន្តិ អនិយមិតបច្ចត្តំ. ន្តិ និយមិត

ឧបយោគំ, ឧភយម្បិ វា យំ តន្តិ បច្ចត្តវចនំ ។ សន្តំ បទន្តិ ឧបយោគវចនំ, តត្ថ លក្ខណតោ សន្តំ, បត្តព្វតោ បទំ, និព្ពានស្សេតំ អធិវចនំ ។ អភិសមេច្ចាតិ អភិសមាគន្ត្វា ។ សក្កោតីតិ សក្កោ, សមត្ថោ បដិពលោតិ វុត្តំ ហោតិ។ ឧជូតិ អជ្ជវយុត្តោ។ សុជុ ឧជូតិ សុហុជុ។ សុខំ វចោ តស្មិន្តិ សុវចោ។ អស្សាតិ ភវេយ្យ ។ មុទូតិ មទ្ទវយុត្តោ។ ន អតិមានីតិ អនតិមានិ ។

អយំ បនេត្ថ អត្ថវណ្ណនា ករណីយមត្ថកុសលេន, យន្តំ សន្តំ បទំ អភិសមេច្ចាតិ ឯត្ថ តាវ អត្ថិ ករណីយំ, អត្ថិ អករណីយំ. តត្ថ សង្ខេបតោ សិក្ខត្តយំ ករណីយំ។ សីលវិបត្តិ, ទិដ្ឋិវិបត្តិ, អាចារវិបត្តិ, អាជីវវិបត្តីតិ ឯវមាទិ អករណីយំ។ តថា អត្ថិ អត្ថកុសលោ, អត្ថិ អនត្ថកុសលោ។ តត្ថ យោ ឥមស្មិំ សាសនេ បព្ពជិត្វា ន អត្តានំ សម្មា បយោជេតិ, ខណ្ឌសីលោ ហោតិ, ឯកវីសតិវិធំ អនេសនំ និស្សាយ ជីវិកំ កប្បេតិ។ សេយ្យថិទំ វេឡុទានំ បត្តទានំ បុប្ផទានំ ផលទានំ ទន្តកដ្ឋទានំ មុខោទកទានំ សិនានទានំ ចុណ្ណទានំ មត្តិកាទានំ ចាដុកម្យតំ មុគ្គសូប្យតំ បារិភដយតំ ជង្ឃបេសនិកំ វេជ្ជកម្មំ ទូតកម្មំ បហិណគមនំ បិណ្ឌបដិបិណ្ឌំ ទានានុប្បទានំ វត្ថុវិជ្ជំ នក្ខត្តវិជ្ជំ អង្គវិជ្ជន្តិ ។ ឆព្ពិធេ ច អគោចរេ ចរតិ។ សេយ្យថិទំ វេសិយាគោចរេ វិធវថុល្លកុមារិកបណ្ឌកភិក្ខុនីបានាគារ - គោចរេតិ។ សំសដ្ឋោ ច វិហរតិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អននុលោមិកេន គិហិសំសគ្គេន, យានិ វា បន តានិ កុលានិ អស្សទ្ធានិ អប្បសន្នានិ អនោបានភូតានិ អក្កោសកបរិភាសកានិ អនត្ថកាមានិ អហិតអផាសុកយោគក្ខេមកាមានិ ភិក្ខូនំ...បេ... ឧបាសិកានំ, តថារូបានិ កុលានិ សេវតិ ភជតិ បយិរុបាសតិ។ អយំ អនត្ថកុសលោ។

យោ បន ឥមស្មិំ សាសនេ បព្ពជិត្វា អត្តានំ សម្មា បយោជេតិ, អនេសនំ បហាយ ចតុបារិសុទ្ធិសីលេ បតិដ្ឋាតុកាមោ សទ្ធាសីសេន បាតិមោក្ខសំវរំ សតិសីសេន ឥន្ទ្រិយសំវរំ វីរិយសីសេន អាជីវបារិសុទ្ធិំ, បញ្ញាសីសេន បច្ចយបដិសេវនំ បូរេតិ។ អយំ អត្ថកុស-លោ។

យោ វា សត្តាបត្តិក្ខន្ធសោធនវសេន បាតិមោក្ខសំវរំ, ឆទ្វារេ ឃដ្ដិតារម្មណេសុ អភិជ្ឈាទីនំ អនុប្បត្តិវសេន ឥន្ទ្រិយសំវរំ, អនេសនបរិវជ្ជនវសេន វិញ្ញុប្បសត្ថពុទ្ធពុទ្ធសា- វកវណ្ណិតបច្ចយបដិសេវនេន ច អាជីវបារិសុទ្ធិំ, យថាវុត្តបច្ចវេក្ខណវសេន បច្ចយបដិ-សេវនំ, ចតុឥរិយាបថបរិវត្តនេ សាត្ថកតាទិបច្ចវេក្ខណវសេន សម្បជញ្ញញ្ច សោធេតិ។ អយម្បិ អត្ថកុសលោ។

យោ វា យថា ឩសោទកំ បដិច្ច សំកិលិដ្ឋំ វត្ថំ បរិយោទាបយតិ, ឆារិកំ បដិច្ច អាទា-សោ, ឧក្កាមុខំ បដិច្ច ជាតរូបំ, តថា ញាណំ បដិច្ច សីលំ វោទាយតីតិ ញត្វា ញាណោទ-កេន ធោវន្តោ សីលំ បរិយោទាបេតិ។ យថា ច កិកី សកុណិកា អណ្ឌំ, ចមរី មិគោ វាលធិំ, ឯកបុត្តិកា នារី បិយំ ឯកបុត្តកំ, ឯកនយនោ បុរិសោ តំ ឯកនយនញ្ច រក្ខតិ, តថា អតិវិយ អប្បមត្តោ អត្តនោ សីលក្ខន្ធំ រក្ខតិ, សាយំ បាតំ បច្ចវេក្ខមានោ អណុមត្តម្បិ វជ្ជំ ន បស្សតិ។ អយម្បិ អត្ថកុសលោ។

យោ វា បន អវិប្បដិសារករេ សីលេ បតិដ្ឋាយ កិលេសវិក្ខម្ភនបដិបទំ បគ្គណ្ហាតិ, តំ បគ្គណ្ហិត្វា កសិណបរិកម្មំ ករោតិ, កសិណបរិកម្មំ កត្វា សមាបត្តិយោ និព្វត្តេតិ។ អយម្បិ អត្ថកុសលោ។

យោ វា បន សមាបត្តិតោ វុដ្ឋាយ សង្ខារេ សម្មសិត្វា អរហត្តំ បាបុណាតិ, អយំ អត្ថកុសលានំ អគ្គោ។ តត្ថ យេ ឥមេ យាវ អវិប្បដិសារករេ សីលេ បតិដ្ឋានេន យាវ វា កិលេសវិក្ខម្ភនបដិបទាយ បគ្គហណេន វណ្ណិតា អត្ថកុសលា, តេ ឥមស្មិំ អត្ថេ អត្ថកុសលាតិ អធិប្បេតា។ តថា វិធា ច តេ ភិក្ខូ។ តេន ភគវា តេ ភិក្ខូ សន្ធាយ ឯកបុគ្គលាធិដ្ឋានាយ ទេសនាយ “ករណីយមត្ថកុសលេនា”តិ អាហ។

តតោ “កឹ ករណីយ”ន្តិ តេសំ សញ្ជាតកង្ខានំ អាហ “យន្តំ សន្តំ បទំ អភិសមេច្ចា”តិ។ អយមេត្ថ អធិប្បាយោ តំ ពុទ្ធានុពុទ្ធេហិ វណ្ណិតំ សន្តំ និព្វានបទំ បដិវេធវសេន អភិសមេ-ច្ច វិ

ហរិតុកាមេន យំ ករណីយន្តិ។ ឯត្ថ ច យន្តិ ឥមស្ស គាថាបទស្ស អាទិតោ វុត្តមេវ ករណីយន្តិ អធិការតោ អនុវត្តតិ, តំ សន្តំ បទំ អភិសមេច្ចាតិ។ អយំ បន យស្មា សាវសេសបាឋោ អត្ថោ, តស្មា វិហរិតុកាមេនាតិ វុត្តន្តិ វេទិតព្វំ។

អថ វា សន្តំ បទំ អភិសមេច្ចាតិ អនុស្សវាទិវសេន លោកិយបញ្ញាយ និព្វានបទំ "សន្ត"ន្តិ ញត្វា តំ អធិគន្តុកាមេន យន្តំ ករណីយន្តិ អធិការតោ អនុវត្តតិ, តំ ករណីយ- មត្ថកុសលេនាតិ ឯវម្បេត្ថ អធិប្បាយោ វេទិតព្វោ។ អថ វា "ករណីយមត្ថកុសលេនា"តិ វុត្តេ "កិ"ន្តិ ចិន្តេន្តានំ អាហ "យន្តំ សន្តំ បទំ អភិសមេច្ចា"តិ។ តស្សេវំ អធិប្បាយោ វេទិត-ព្វោ លោកិយបញ្ញាយ សន្តំ បទំ អភិសមេច្ច យំ ករណីយំ កាតព្វំ, តំ ករណីយំ, ករណារហមេវ តន្តិ វុត្តំ ហោតិ។

កឹ បន តន្តិ? កិមញ្ញំ សិយា អញ្ញត្រ តទធិគមុបាយតោ, កាមញ្ចេតំ ករណារហដ្ឋេន សិក្ខត្តយទីបកេន អាទិបទេនេវ វុត្តំ។ តថា ហិ តស្ស អត្ថវណ្ណនាយំ អវោចុម្ហា "អត្ថិ ករណីយំ, អត្ថិ អករណីយំ។ តត្ថ សង្ខេបតោ សិក្ខត្តយំ ករណីយ"ន្តិ។ អតិសង្ខេបេន ទេសិតត្តា បន តេសំ ភិក្ខូនំ កេហិចិ វិញ្ញាតំ, កេហិចិ ន វិញ្ញាតំ។ តតោ យេហិ ន វិញ្ញាតំ, តេសំ វិញ្ញាបនត្ថំ យំ វិសេសតោ អារញ្ញកេន ភិក្ខុនា កាតព្វំ, តំ វិត្ថារេន្តោ "សក្កោ ឧជូ ច សុហុជូ ច, សុវចោ ចស្ស មុទុ អនតិមានី"តិ ឥមំ តាវ ឧបឌ្ឍគាថមាហ។

កឹ វុត្តំ ហោតិ? សន្តំ បទំ អភិសមេច្ច វិហរិតុកាមោ, លោកិយបញ្ញាយ វា តំ អភិសមេច្ច តទធិគមាយ បដិបជ្ជមានោ អារញ្ញកោ ភិក្ខុ ទុតិយចតុត្ថបធានិយង្គសម -ន្នាគមេន កាយេ ច ជីវិតេ ច អនបេក្ខោ ហុត្វា សច្ចប្បដិវេធាយ បដិបជ្ជិតុំ សក្កោ អស្ស, តថា កសិណបរិកម្មវត្តសមាទានាទីសុ អត្តនោ បត្តចីវរប្បដិសង្ខរណាទីសុ ច យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹ ករណីយានិ, តេសុ អញ្ញេសុ ច ឯវរូបេសុ សក្កោ អស្ស ទក្ខោ អនលសោ សមត្ថោ។ សក្កោ ហោន្តោបិ ច តតិយបធានិយង្គសមន្នាគមេន ឧជុ អស្ស។ ឧជុ ហោន្តោបិ ច ស

កឹ ឧជុភាវេន ទហរកាលេ វា ឧជុភាវេន សន្តោសំ អនាបជ្ជិត្វា យាវជីវំ បុនប្បុនំ អសិថិលករណេន សុដ្ឋុតរំ ឧជុ អស្ស។ អសឋតាយ វា ឧជុ, អមាយាវិតាយ សុហុជុ។ កាយវចីវង្កប្បហានេន វា ឧជុ, មនោវង្កប្បហានេន សុហុជុ។ អសន្តគុណស្ស វា អនាវិករណេន ឧជុ, អសន្តគុណេន ឧប្បន្នស្ស លាភស្ស អនធិវាសនេន សុហុជុ។ ឯវំ អារម្មណលក្ខណូបនិជ្ឈានេហិ បុរិមទ្វយតតិយសិក្ខាហិ បយោគាសយសុទ្ធីហិ ច ឧជុ ច សុហុជុ ច អស្ស។

ន កេវលញ្ច ឧជុ ច សុហុជុ ច, អបិច បន សុវចោ ច អស្ស។ យោ ហិ បុគ្គលោ "ឥទំ ន កត្តព្វ"ន្តិ វុត្តោ "កឹ តេ ទិដ្ឋំ, កឹ តេ សុតំ, កោ មេ សុត្វា វទសិ, កឹ ឧបជ្ឈាយោ អាចរិយោ សន្ទិដ្ឋោ សម្ភត្តោ វា"តិ វទេតិ, តុណ្ហីភាវេន វា តំ វិហេសេតិ, សម្បដិច្ឆិត្វា វា ន តថា ករោតិ, សោ វិសេសាធិគមស្ស ទូរេ ហោតិ។ យោ បន ឱវទិយមានោ "សាធុ, ភន្តេ សុដ្ឋុ វុត្តំ, អត្តនោ វជ្ជំ នាម ទុទ្ទសំ ហោតិ, បុនបិ មំ ឯវរូបំ ទិស្វា វទេយ្យាថ អនុកម្បំ ឧបាទាយ, ចិរស្សំ មេ តុម្ហាកំ សន្តិកា ឱវាទោ លទ្ធោ"តិ វទតិ, យថានុសិដ្ឋញ្ច បដិបជ្ជតិ, សោ វិសេសាធិគមស្ស អវិទូរេ ហោតិ។ តស្មា ឯវំ បរស្ស វចនំ សម្បដិច្ឆិត្វា ករោន្តោ សុវចោ ច អស្ស។

យថា ច សុវចោ, ឯវំ មុទុ អស្ស។ មុទូតិ គហដ្ឋេហិ ទូតគមនបហិណគមនាទីសុ និយុជ្ជមានោ តត្ថ មុទុភាវំ អកត្វា ថទ្ធោ ហុត្វា វត្តបដិបត្តិយំ សកលព្រហ្មចរិយេ ច មុទុ អស្ស សុបរិកម្មកតសុវណ្ណំ វិយ តត្ថ តត្ថ វិនិយោគក្ខមោ។ អថ វា មុទូតិ អភាកុដិកោ ឧត្តានមុខោ សុខសម្ភាសោ បដិសន្ថារវុត្តិ សុតិត្ថំ វិយ សុខាវគាហោ អស្ស។ ន កេវលញ្ច មុទុ, អបិច បន អនតិមានី អស្ស, ជាតិគោត្តាទីហិ អតិមានវត្ថូហិ បរេ នាតិមញ្ញេយ្យ, សារិបុត្តត្ថេរោ វិយ ចណ្ឌាលកុមារកសមេន ចេតសា វិហរេយ្យាតិ។

## ទុតិយគាថាវណ្ណនា

២.ឯវំ ភគវា សន្តំ បទំ អភិសមេច្ច វិហរិតុកាមស្ស តទធិគមាយ វា បដិបជ្ជមានស្ស វិសេសតោ អារញ្ញកស្ស ភិក្ខុនោ ឯកច្ចំ ករណីយំ វត្វា បុន តតុត្តរិបិ វត្តុកាមោ “សន្តុស្សកោ ចា”តិ ទុតិយគាថមាហ។

តត្ថ “សន្តុដ្ឋី ច កតញ្ញុតា”តិ ឯត្ថ វុត្តប្បភេទេន ទ្វាទសវិធេន សន្តោសេន សន្តុស្សតី-តិ សន្តុស្សកោ។ អថ វា តុស្សតីតិ តុស្សកោ, សកេន តុស្សកោ, សន្តេន តុស្សកោ, សមេន- តុស្សកោតិ សន្តុស្សកោ។ តត្ថ សកំ នាម “បិណ្ឌិយាលោបភោជនំ និស្សាយា”តិ ឯវំ ឧបសម្បទមណ្ឌលេ ឧទ្ទិដ្ឋំ អត្តនា ច សម្បដិច្ឆិតំ ចតុបច្ចយជាតំ, តេន សុន្ទរេន វា អសុន្ទ-រេន វា សក្កច្ចំ វា អសក្កច្ចំ វា ទិន្នេន បដិគ្គហណកាលេ បរិភោគកាលេ ច វិការំ អទស្សេត្វា យាបេន្តោ “សកេន តុស្សកោ”តិ វុច្ចតិ។ សន្តំ នាម យំ លទ្ធំ ហោតិ អត្តនោ ‘វិជ្ជមានំ, តេន សន្តេនេវ តុស្សន្តោ តតោ បរំ ន បត្ថេន្តោ អត្រិច្ឆតំ បជហន្តោ “សន្តេន តុស្សកោ”តិ វុច្ចតិ។ សមំ នាម ឥដ្ឋានិដ្ឋេសុ អនុនយបដិឃប្បហានំ, តេន សមេន សព្វារម្មណេសុ តុស្សន្តោ “សមេន តុស្សកោ”តិ វុច្ចតិ។

សុខេន ភរីយតីតិ សុភរោ, សុបោសោតិ វុត្តំ ហោតិ. យោ ហិ ភិក្ខុ មនុស្សេហិ សាលិមំសោទនាទីនំ បត្តេ បូរេត្វា ទិន្នេបិ ទុម្មុខភាវំ អនត្តមនភាវមេវ ច ទស្សេតិ, តេសំ វា សម្មុខាវ តំ បិណ្ឌបាតំ “កិំ តុម្ហេហិ ទិន្ន”ន្តិ អបសាទេន្តោ សាមណេរគហដ្ឋាទីនំ ទេតិ, ឯស ទុព្ភរោ។ ឯតំ ទិស្វា មនុស្សា ទូរតោវ បរិវជ្ជេន្តិ “ទុព្ភរោ ភិក្ខុ ន សក្កា បោសេតុ”ន្តិ។ យោ បន យំ កិញ្ចិ លូខំ វា បណីតំ វា អប្បំ វា ពហុំ វា លភិត្វា អត្តមនោ វិប្បសន្នមុខោ ហុត្វា យាបេតិ, ឯស សុភរោ។ ឯតំ ទិស្វា មនុស្សា អតិវិយ វិស្សត្ថា ហោន្តិ, “អម្ហាកំ ភទន្តោ សុភរោ, ថោកថោកេនាបិ តុស្សតិ, មយមេវ នំ បោសេស្សាមា”តិ បដិញ្ញំ កត្វា បោសេន្តិ។ ឯវរូបោ ឥធ សុភរោតិ អធិប្បេតោ។

អប្បំ កិច្ចមស្សាតិ អប្បកិច្ចោ, ន កម្មារាមតាភស្សារាមតាសង្គណិការាមតាទិអនេក-
កិច្ចព្យាវដោ, អថ វា សកលវិហារេ នវកម្មសង្ឃបរិភោគសាមណេរអារាមិកវោសាសនា- ទិ
កិច្ចវិរហិតោ, អត្តនោ កេសនខច្ឆេទនបត្តចីវរកម្មាទិំ កត្វា សមណធម្មកិច្ចបរោ ហោតីតិ វុត្តំ
ហោតិ។

សល្លហុកា វុត្តិ អស្សាតិ សល្លហុកវុត្តិ។ យថា ឯកច្ចោ ពហុភណ្ឌោ ភិក្ខុ ទិសាបក្កមន
កាលេ ពហុំ បត្តចីវរបច្ចត្ថរណតេលគុឡាទិំ មហាជនេន សីសភារកដិភារាទីហិ ឧព្វ- ហា
បេត្វា បក្កមតិ, ឯវំ អហុត្វា យោ អប្បបរិក្ខារោ ហោតិ, បត្តចីវរាទិអដ្ឋសមណបរិក្ខា- រមត្ត
មេវ បរិហរតិ, ទិសាបក្កមនកាលេ បក្ខី សកុណោ វិយ សមាទាយេវ បក្កមតិ, ឯវរូបោ ឥធ
សល្លហុកវុត្តីតិ អធិប្បេតោ។ សន្តានិ ឥន្ទ្រិយានិ អស្សាតិ សន្តិន្ទ្រិយោ, ឥដ្ឋារម្មណា- ទីសុ
រាគាទិវសេន អនុទ្ធតិន្ទ្រិយោតិ វុត្តំ ហោតិ។ និបកោតិ វិញ្ញូ វិភាវី បញ្ញវា, សីលានុរក្ខ-ណ
បញ្ញាយ ចីវរាទិវិចារណបញ្ញាយ អាវាសាទិសត្តសប្បាយបរិជាននបញ្ញាយ ច សម-ន្នាគ
តោតិ អធិប្បាយោ។

ន បគព្ភោតិ អប្បគព្ភោ, អដ្ឋដ្ឋានេន កាយបាគព្ភិយេន ចតុដ្ឋានេន វចីបាគព្ភិយេន អ
នេកេន ថានេន មនោបាគព្ភិយេន ច វិរហិតោតិ អត្ថោ។

អដ្ឋដ្ឋានំ កាយបាគព្ភិយំ នាម សង្ឃគណបុគ្គលភោជនសាលាជន្តាឃរន្ហានតិត្ថ-ភិក្ខា
ចារមគ្គអន្តរឃរប្បវេសនេសុ កាយេន អប្បតិរូបករណំ។ សេយ្យថិទំ ឥធេកច្ចោ សង្ឃមជ្ឈេ
បល្លត្ថិកាយ វា និសីទតិ បាទេ បាទមោទហិត្វា វាតិ ឯវមាទិ។ តថា គណម -ជ្ឈេ ចតុបរិស
សន្និបាតេ, តថា វុឌ្ឍតរេ បុគ្គលេ។ ភោជនសាលាយំ បន វុឌ្ឍានំ អាសនំ ន ទេតិ, នវានំ
អាសនំ បដិពាហតិ។ តថា ជន្តាឃរេ, វុឌ្ឍេ ចេត្ថ អនាបុច្ឆា អគ្គិជាលនាទីនិ ករោតិ។ ន្ហានតិ
ត្ថេ ច យទិទំ "ទហរោ វុឌ្ឍោតិ បមាណំ អកត្វា អាគតបដិបាដិយា ន្ហាយិតព្ព"ន្តិ វុត្តំ, ត
ម្បិ អនាទិយន្តោ បច្ឆា អាគន្ត្វា ឧទកំ ឱតរិត្វា វុឌ្ឍេ ច នវេ ច ពាធេតិ។ ភិក្ខាចារមគ្គេ បន អ

គ្គាសនអគ្គោទកអគ្គបិណ្ឌគ្គំ វុឌ្ឍានំ បុរតោ បុរតោ យាតិ, ពាហាយ ពាហំ បហរន្តោ។ អន្តរឃរប្បវេសនេ វុឌ្ឍានំ បឋមតរំ បវិសតិ, ទហរេហិ កាយកីឡនំ ករោតីតិ ឯវមាទិ។

ចតុដ្ឋានំ វចីបាគព្ភិយំ នាម សង្ឃគណបុគ្គលអន្តរឃរេសុ អប្បតិរូបវាចានិច្ឆារណំ សេយ្យថិទំ ឥធេកច្ចោ សង្ឃមជ្ឈេ អនាបុច្ឆា ធម្មំ ភាសតិ, តថា បុព្វេ វុត្តប្បការេ គណេ វុឌ្ឍតរេ បុគ្គលេ ច, តត្ថ មនុស្សេហិ បញ្ហំ បុដ្ឋោ វុឌ្ឍតរំ អនាបុច្ឆា វិស្សជ្ជេតិ, អន្តរឃរេ បន "ឥត្ថន្នាមេ កឹ អត្ថិ, កឹ យាគុ ឧទាហុ ខាទនីយំ វា ភោជនីយំ វា, កឹ មេ ទស្សសិ, កឹ អជ្ជ ខាទិស្សាមិ, កឹ ភុញ្ជិស្សាមិ, កឹ បិវិស្សាមី"តិ ឯវមាទឹ ភាសតិ។

អនេកដ្ឋានំ មនោបាគព្ភិយំ នាម តេសុ តេសុ ឋានេសុ កាយវាចាហិ អជ្ឈាចារំ អនាបជ្ជិត្វាបិ មនសា ឯវ កាមវិតក្កាទិនានប្បការំ អប្បតិរូបវិតក្កនំ។

កុលេស្វននុគិទ្ធោតិ យានិ តានិ កុលានិ ឧបសង្កមតិ, តេសុ បច្ចយតណ្ហាយ វា អននុលោមិកគិហិសំសគ្គវសេន វា អននុគិទ្ធោ, ន សហសោកី, ន សហនន្ទី, ន សុខិតេសុ សុខិតោ, ន ទុក្ខិតេសុ ទុក្ខិតោ, ន ឧប្បន្នេសុ កិច្ចករណីយេសុ អត្តនា វា ឧយ្យោគមាបជ្ជិ-តាតិ វុត្តំ ហោតិ។ ឥមិស្សាយ ច គាថាយ យំ "សុវចោ ចស្សា"តិ ឯត្ថ វុត្តំ អស្សាតិ វចនំ, តំ សព្វបទេហិ សទ្ធឹ សន្តុស្សកោ ច អស្ស, សុភរោ ច អស្សាតិ ឯវំ យោជេតព្វំ។

## តតិយគាថាវណ្ណនា

៣ .ឯវំ ភគវា សន្តំ បទំ អភិសមេច្ច វិហរិតុកាមស្ស តទធិគមាយ វា បដិបជ្ជិតុកាម-ស្ស វិសេសតោ អារញ្ញកស្ស ភិក្ខុនោ តទុត្តរិបិ ករណីយំ អាចិក្ខិត្វា ឥទានិ អករណីយម្បិ អាចិក្ខិតុកាមោ "ន ច ខុទ្ទមាចរេ កិញ្ចិ, យេន វិញ្ញូ បរេ ឧបវទេយ្យុ"ន្តិ ឥមំ ឧបឌ្ឍគាថមា-ហ។

តស្សត្ថោ ឯវមិមំ ករណីយំ ករោន្តោ យំ តំ កាយវចីមនោទុច្ចរិតំ ខុទ្ទំ លាមកន្តិ វុច្ច-តិ, តំ ន ច ខុទ្ទំ សមាចរេ, អសមាចរន្តោ ច ន កេវលំ ឱឡារិកំ, កិន្តុ កិញ្ចិ ន សមាចរេ, អប្បមត្តកម្បិ អណុមត្តកម្បិ ន សមាចរេតិ វុត្តំ ហោតិ។

តតោ តស្ស សមាចារេ សន្ទិដ្ឋិកមេវាទីនវំ ទស្សេតិ “យេន វិញ្ញូ បរេ ឧបវទេយ្យុ”ន្តិ ។ ឯត្ថ ច យស្មា អវិញ្ញូ បរេ អប្បមាណំ ។ តេ ហិ អនវជ្ជំ វា សាវជ្ជំ ករោន្តិ, អប្បសាវជ្ជំ វា មហាសាវជ្ជំ ។ វិញ្ញូ ឯវ បន បមាណំ ។ តេ ហិ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសន្តិ, វណ្ណារហស្ស វណ្ណំ ភាសន្តិ ។ តស្មា “វិញ្ញូ បរេ”តិ វុត្តំ ។

ឯវំ ភគវា ឥមាហិ អឌ្ឍតេយ្យាហិ គាថាហិ សន្តំ បទំ អភិសមេច្ច វិហរិតុកាមស្ស តទធិគមាយ វា បដិបជ្ជិតុកាមស្ស វិសេសតោ អារញ្ញកស្ស, អារញ្ញកសីលេន ច សព្វស-ម្បិ កម្មដ្ឋានំ គហេត្វា វិហរិតុកាមានំ ករណីយាករណីយភេទំ កម្មដ្ឋានូបចារំ វត្វា ឥទានិ តេសំ ភិក្ខូនំ តស្ស ទេវតាភយស្ស បដិឃាតាយ បរិត្តត្ថំ វិបស្សនាបាទកជ្ឈានវសេន កម្មដ្ឋានត្ថញ្ច “សុខិនោវ ខេមិនោ ហោន្តូ”តិអាទិនា នយេន មេត្តកថំ កថេតុមារទ្ធោ ។

តត្ថ សុខិនោតិ សុខសម្បន្នា ។ ខេមិនោតិ ខេមវន្តោ, អភយា និរុបទ្ទវាតិ វុត្តំ ហោតិ ។ សព្វេតិ អនវសេសា ។ សត្តាតិ បាណិនោ ។ សុខិតត្តាតិ សុខិតចិត្តា ។ ឯត្ថ ច កាយិកេន សុខេន សុខិនោ, មានសេន សុខិតត្តា, តទុភយេនាបិ សព្វភយុបទ្ទវវិគមេន វា ខេមិនោតិ វេទិតព្វោ ។ កស្មា បន ឯវំ វុត្តំ? មេត្តាភាវនាការទស្សនត្ថំ ។ ឯវញ្ហិ មេត្តា ភាវេតព្វា “សព្វេ- សត្តា សុខិនោ ហោន្តូ”តិ វា, “ខេមិនោ ហោន្តូ”តិ វា, “សុខិតត្តា ហោន្តូ”តិ វា ។

## ចតុត្ថគាថាវណ្ណនា

៤.ឯវំ យាវ ឧបចារតោ អប្បនាកោដិ, តាវ សង្ខេបេន មេត្តាភាវនំ ទស្សេត្វា ឥទានិ វិត្ថារតោបិ តំ ទស្សេតុំ “យេ កេចី”តិ គាថាទ្វយមាហ ។ អថ វា យស្មា បុថុត្តារម្មណេ បរិចិតំ ចិត្តំ ន អាទិកេនេវ ឯកត្តេ សណ្ឋាតិ អារម្មណប្បភេទំ បន អនុគន្ត្វា អនុគន្ត្វា កមេន សណ្ឋាតិ, តស្មា តស្ស តសថាវរាទិទុកតិកប្បភេទេ អារម្មណេ អនុគន្ត្វា អនុគន្ត្វា សណ្ឋានត្ថម្បិ “យេ កេចី”តិ គាថាទ្វយមាហ ។ អថ វា យស្មា យស្ស យំ អារម្មណំ វិភូតំ ហោតិ, តស្ស ត

ត្ថ ចិត្តំ សុខំ តិដ្ឋតិ, តស្មា តេសំ ភិក្ខូនំ យស្ស យំ វិភូតំ អារម្មណំ, តស្ស  តត្ថ ចិត្តំ សណ្ឋាបេតុកាមោ តសថាវរាទិទុកតិការម្មណភេទទីបកំ “យេ កេចី”តិ ឥមំ  គាថាទ្វយមាហ។

ឯត្ថ ហិ តសថាវរទុកំ ទិដ្ឋាទិដ្ឋទុកំ ទូរសន្តិកទុកំ ភូតសម្ភវេសិទុកន្តិ ចត្តារោ ទុកេ,  ទីឃាទីហិ ច ឆហិ បទេហិ មជ្ឈិមបទស្ស តីសុ អណុកបទស្ស ច ទ្វីសុ តិកេសុ អត្ថសម្ភ-វតោ ទីឃរស្សមជ្ឈិមតិកំ មហន្តាណុកមជ្ឈិមតិកំ ថូលាណុកមជ្ឈិមតិកន្តិ តយោ តិកេ ច ទីបេតិ។ តត្ថ យេ កេចីតិ អនវសេសវចនំ។ បាណា ឯវ ភូតា បាណភូតា។ អថ វា បាណន្តីតិ បាណា, ឯតេន អស្សាសបស្សាសប្បដិពទ្ធេ បញ្ចវោការសត្តេ គណ្ហាតិ។ ភវន្តីតិ ភូតា, ឯតេន ឯកវោការចតុវោការសត្តេ គណ្ហាតិ។ អត្ថីតិ សន្តិ សំវិជ្ជន្តិ។

ឯវំ “យេ កេចិ បាណភូតត្ថី”តិ ឥមិនា វចនេន ទុកតិកេហិ សង្គហេតព្វេ សព្វសត្តេ ឯកតោ ទស្សេត្វា ឥទានិ សព្ពេបិ តេ តសា វា ថាវរា វ នវសេសាតិ ឥមិនា ទុកេន សង្គហេត្វា ទស្សេតិ។

តត្ថ តសន្តីតិ តសា, សតណ្ហានំ សភយានញ្ចេតំ អធិវចនំ។ តិដ្ឋន្តីតិ ថាវរា, បហីនតណ្ហាភយានំ អរហតំ ឯតំ អធិវចនំ។ នត្ថិ តេសំ អវសេសន្តិ អនវសេសា, សព្ពេបីតិ វុត្តំ ហោតិ។ យញ្ច ទុតិយគាថាយ អន្តេ វុត្តំ, តំ សព្ពទុកតិកេហិ សម្ពន្ធិតព្ពំ “យេ កេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា, ឥមេបិ សព្វេ សត្តា ភវន្តុ សុខិតត្តា។ ឯវំ យាវ ភូតា វា សម្ភវេសី វា, ឥមេបិ សព្វេ សត្តា ភវន្តុ សុខិតត្តា”តិ។

ឥទានិ ទីឃរស្សមជ្ឈិមាទិតិកត្តយទីបកេសុ ទីឃា វាតិអាទីសុ ឆសុ បទេសុ ទីឃាតិ ទីឃត្តភាវា នាគមច្ឆគោធាទយោ។ អនេកព្យាមសតប្បមាណាបិ ហិ មហាសមុទ្ទេ នាគានំ អត្តភាវា អនេកយោជនប្បមាណា ច មច្ឆគោធាទីនំ អត្តភាវា ហោន្តិ។ មហន្តាតិ មហន្តត្តភាវា ជលេ មច្ឆកច្ឆបាទយោ, ថលេ ហត្ថិនាគាទយោ, អមនុស្សេសុ ទានវាទយោ។ អាហ ច “រាហុគ្គំ អត្តភាវីន”ន្តិ។ តស្ស ហិ អត្តភាវោ ឧព្ពេធេន ចត្តារិ យោជនសហស្សានិ អដ្ឋ ច យោ

ផនសតានិ, ពាហូ ទ្វេ ទសយោជនសតបរិមាណា, បញ្ញាសយោជនំ កមុកន្ទរំ, តថា អង្គុលន្តរិកា, ហត្ថតលានិ ទ្វេ យោជនសតានីតិ។ មជ្ឈិមាតិ អស្សគោណមហិំសសូករាទិ-នំ អត្តភាវា។ វស្សកាតិ តាសុ តាសុ ជាតីសុ វាមនាទយោ ទីឃមជ្ឈិមេហិ ឱមកប្បមាណា -សត្តា។ អណុកាតិ មំសចក្ខុស្ស អគោចរា ទិព្ពចក្ខុវិសយា ឧទកាទីសុ និព្ពត្តា សុខុមត្តភាវា សត្តា ឩកាទយោ វា។ អបិច យេ តាសុ តាសុ ជាតីសុ មហន្តមជ្ឈិមេហិ ថូលមជ្ឈិមេហិ ច ឱមកប្បមាណា សត្តា, តេ អណុកាតិ វេទិតព្វា។ ថូលាតិ បរិមណ្ឌលត្តភាវា សិប្បិកសម្ពុ-កាទយោ សត្តា។

## បញ្ចមគាថាវណ្ណនា

៥.ឯវំ តីហិ តិកេហិ អនវសេសតោ សត្តេ ទស្សេត្វា ឥទានិ "ទិដ្ឋា វា យេ វ អទិដ្ឋា"តិអាទីហិ តីហិ ទុកេហិបិ តេ សង្គហេត្វា ទស្សេតិ។

តត្ថ ទិដ្ឋាតិ យេ អត្តនោ ចក្ខុស្ស អាបាថមាគតវសេន ទិដ្ឋបុព្ពា។ អទិដ្ឋាតិ យេ បរ-សមុទ្ទបរសេលបរចក្កវាឡាទីសុ ឋិតា។ "យេ វា ទូរេ វសន្តិ អវិទូរេ"តិ ឥមិនា បទទុកេន អត្តនោ អត្តភាវស្ស ទូរេ ច អវិទូរេ ច វសន្តេ សត្តេ ទស្សេតិ, តេ អបទទិបទវសេន វេទិត-ព្វា។ អត្តនោ ហិ កាយេ វសន្តា សត្តា អវិទូរេ, ពហិកាយេ វសន្តា សត្តា ទូរេ។ តថា អន្តោឧបចារេ វសន្តា អវិទូរេ, ពហិឧបចារេ វសន្តា ទូរេ។ អត្តនោ វិហារេ គាមេ ជនបទេ ទីបេ ចក្កវាឡេ វសន្តា អវិទូរេ, បរចក្កវាឡេ វសន្តា ទូរេ វសន្តីតិ វុច្ចន្តិ។

ភូតាតិ ជាតា អភិនិព្វត្តា។ យេ ភូតា ឯវ, ន បុន ភវិស្សន្តីតិ សង្ខ្យំ គច្ឆន្តិ, តេសំ ខីណាសវានំ ឯតំ អធិវចនំ. សម្ភវេសន្តីតិ សម្ភវេសី. អប្បហីនភវសំយោជនត្តា អាយតិ-ម្បិ សម្ភវំ ឯសន្តានំ សេខបុថុជ្ជនានមេតំ អធិវចនំ. អថ វា ចតូសុ យោនីសុ អណ្ឌជជ-លាពុជា សត្តា យាវ អណ្ឌកោសំ វត្ថិកោសញ្ច ន ភិន្ទន្តិ, តាវ សម្ភវេសី នាម, អណ្ឌកោសំ វត្ថិកោសញ្ច ភិន្ទិត្វា ពហិ និក្ខន្តា ភូតា នាម។ សំសេទជា ឱបបាតិកា ច បឋមចិត្តក្ខណេ សម្ភវេសី នាម,

ទុតិយចិត្តក្ខណតោ បភុតិ ភូតា នាម។ យេន វា ឥរិយាបថេន ជាយន្តិ, យាវ តតោ អញ្ញំ ន បាបុណន្តិ, តាវ សម្ភវេសី នាម, តតោ បរំ ភូតាតិ។

## ឆដ្ឋគាថាវណ្ណនា

៦.ឯវំ ភគវា “សុខិនោ វា”តិអាទីហិ អឌ្ឍតេយ្យាហិ គាថាហិ នានប្បការតោ តេសំ ភិក្ខូនំ ហិតសុខាគមបត្ថនាវសេន សត្តេសុ មេត្តាភាវនំ ទស្សេត្វា ឥទានិ អហិតទុក្ខានាគ- មបត្ថនាវសេនាបិ តំ ទស្សេន្តោ អាហ “ន បរោ បរំ និកុព្ពេថា”តិ។ ឯស បោរាណោ បាឋោ, ឥទានិ បន “បរំ ហី”តិបិ បឋន្តិ, អយំ ន សោភនោ។

តត្ថ បរោតិ បរជនោ។ បរន្តិ បរជនំ។ន និកុព្ពេថាតិ ន វញ្ចេយ្យ។ នាតិមញ្ញេថាតិ ន អតិក្កមិត្វា មញ្ញេយ្យ។ កត្ថចីតិ កត្ថចិ ឱកាសេ, គាមេ វា គាមខេត្តេ វា ញាតិមជ្ឈេ វា បូគមជ្ឈេ វាតិអាទិ។ នន្តិ ឯតំ។ កញ្ចីតិ យំ កញ្ចិ ខត្តិយំ វា ព្រាហ្មណំ វា គហដ្ឋំ វា បព្ពជិតំ វា សុខិតំ វា ទុក្ខិតំ វាតិអាទិ. ព្យារោសនា បដិឃសញ្ញាតិ កាយវចីវិការេហិ ព្យារោសនាយ ច មនោវិការេន បដិឃសញ្ញាយ ច. “ព្យារោសនាយ បដិឃសញ្ញាយា”តិ ហិ វត្តព្ពេ “ព្យា-រោសនា បដិឃសញ្ញា”តិ វុច្ចតិ, យថា “សម្មទញ្ញាយ វិមុត្តា”តិ វត្តព្ពេ “សម្មទញ្ញា វិមុត្តា”តិ, យថា ច “អនុបុព្ពសិក្ខាយ អនុបុព្ពកិរិយាយ អនុបុព្ពបដិបទាយា”តិ វត្តព្ពេ “អនុបុព្ពសិក្ខា អនុបុព្ពកិរិយា អនុបុព្ពបដិបទា”តិ។ នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យាតិ អញ្ញមញ្ញស្ស ទុក្ខំ ន ឥច្ឆេយ្យ ។ កិំ វុត្តំ ហោតិ? ន កេវលំ “សុខិនោ វា ខេមិនោ វា ហោន្តូ”តិអាទិមនសិការវសេ-នេវ មេត្តំ ភាវេយ្យ, កិន្តុ “អហោ វត យោ កោចិ បរបុគ្គលោ យំ កញ្ចិ បរបុគ្គលំ វញ្ចនាទីហិ និកតីហិ ន និកុព្ពេថ, ជាតិអាទីហិ ច នវហិ មានវត្ថូហិ កត្ថចិ បទេសេ កញ្ចិ បរបុគ្គលំ នាតិមញ្ញេយ្យ, អញ្ញមញ្ញស្ស ច ព្យារោសនាយ វា បដិឃសញ្ញាយ វា ទុក្ខំ ន ឥច្ឆេយ្យា”តិ ឯវម្បិ មនសិករោន្តោ ភាវេយ្យាតិ។

## សត្តមគាថាវណ្ណនា

៧ .ឯវំ អហិតទុក្ខានាគមបត្ថនាវសេន អត្ថតោ មេត្តាភាវនំ ទស្សេត្វា ឥទានិ តមេវ ឧបមាយ ទស្សេន្តោ អាហ "មាតា យថា និយំបុត្ត"ន្តិ ។

តស្សត្ថោ យថា មាតា និយំ បុត្តំ អត្តនិ ជាតំ ឱរសំ បុត្តំ, តញ្ច ឯកបុត្តមេវ អាយុសា អនុរក្ខេ, តស្ស ទុក្ខាគមប្បដិពាហនត្ថំ អត្តនោ អាយុម្បិ ចជិត្វា តំ អនុរក្ខេ, ឯវម្បិ សព្វភូតេសុ ឥទំ មេត្តាខ្យំ មានសំ ភាវយេ, បុនប្បុនំ ជនយេ វឌ្ឍយេ, តញ្ច អបរិមាណសត្តារម្មណវសេន ឯកស្មឹ វា សត្តេ អនវសេសផរណវសេន អបរិមាណំ ភាវយេតិ។

## អដ្ឋមគាថាវណ្ណនា

៨.ឯវំ សព្វាការេន មេត្តាភាវនំ ទស្សេត្វា ឥទានិ តស្សេវ វឌ្ឍនំ ទស្សេន្តោ អាហ "មេត្តញ្ច សព្វលោកស្មឹ"តិ។

តត្ថ មិជ្ជតិ តាយតិ ចាតិ មិត្តោ, ហិតជ្ឈាសយតាយ សិនិយ្ហតិ, អហិតាគមតោ រក្ខតិ ចាតិ អត្ថោ។ មិត្តស្ស ភាវោ មេត្តំ។ សព្វលោកស្មឹតិ អនវសេសេ សត្តលោកេ។ មនសិ ភវន្តិ មានសំ។ តញ្ហិ ចិត្តសម្បយុត្តត្តា ឯវំ វុត្តំ។ ភាវយេតិ វឌ្ឍយេ។ ន អស្ស បរិមាណន្តិ អបរិមាណំ, អប្បមាណសត្តារម្មណតាយ ឯវំ វុត្តំ។ ឧទ្ធន្តិ ឧបរិ, តេន អរូបភវំ គណ្ហាតិ។ អធោតិ ហេដ្ឋា, តេន កាមភវំ គណ្ហាតិ។ តិរិយន្តិ វេមជ្ឈំ, តេន រូបភវំ គណ្ហាតិ។ អសម្ពាធ-ន្តិ សម្ពាធវិរហិតំ, ភិន្នសីមន្តិ វុត្តំ ហោតិ។ សីមា នាម បច្ចត្ថិកោ វុច្ចតិ, តស្មិម្បិ បវត្តន្តិ អត្ថោ។ អវេរន្តិ វេរវិរហិតំ, អន្តរន្តរាបិ វេរចេតនាបាតុភាវវិរហិតន្តិ អត្ថោ។ អសបត្តន្តិ វិគត- បច្ចត្ថិកំ។ មេត្តាវិហារី ហិ បុគ្គលោ មនុស្សានំ បិយោ ហោតិ, អមនុស្សានំ បិយោ ហោតិ, នាស្ស កោចិ បច្ចត្ថិកោ ហោតិ, តេនស្ស តំ មានសំ វិគតបច្ចត្ថិកត្តា អសបត្តន្តិ វុច្ចតិ។ បរិយាយវចនញ្ហិ ឯតំ, យទិទំ បច្ចត្ថិកោ សបត្តោតិ។ អយំ អនុបទតោ អត្ថវណ្ណនា។

អយំ បនេត្ថ អធិប្បេតត្ថទីបនា យទិទំ ‘‘ឯវម្បិ សព្ពភូតេសុ មានសំ ភាវយេ អបរិមាណ’’ន្តិ វុត្តំ, តញ្ច តំ អបរិមាណំ មេត្តំ មានសំ សព្ពលោកស្មិំ ភាវយេ វឌ្ឍយេ, វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ គមយេ បាបយេ។ កថំ? ឧទ្ធំ អធោ ច តិរិយញ្ច, ឧទ្ធំ យាវ ភវគ្គា, អធោ យាវ អវីចិតោ, តិរិយំ យាវ អវសេសទិសា។ ឧទ្ធំ វា អារុប្បំ, អធោ កាមធាតុំ, តិរិយំ រូបធាតុំ អនវសេសំ ផរន្តោ។ ឯវំ ភាវេន្តោបិ ច តំ យថា អសម្ពាធំ អវេរំ អសបត្តញ្ច ហោតិ, តថា សម្ពាធវេរសបត្តានំ អភាវំ ករោន្តោ ភាវយេ។ យំ វា តំ ភាវនាសម្បទំ បត្តំ សព្វត្ថ ឱកាស-លោកវសេន អសម្ពាធំ, អត្តនោ បរេសុ អាឃាតប្បដិវិនយនេន អវេរំ, អត្តនិ ច បរេសំ អាឃាតវិនយនេន អសបត្តំ ហោតិ។ តំ អសម្ពាធមវេរមសបត្តំ អបរិមាណំ មេត្តំ មានសំ ឧទ្ធំ អធោ តិរិយញ្ចាតិ តិវិធបរិច្ឆេទេ សព្វលោកស្មិំ ភាវយេ វឌ្ឍយេតិ។

នវមគាថាវណ្ណនា

៩. ឯវំ មេត្តាភាវនាយ វឌ្ឍនំ ទស្សេត្វា ឥទានិ តំ ភាវនមនុយុត្តស្ស វិហរតោ ឥរិយាបថនិយមាភាវំ ទស្សេន្តោ អាហ ‘‘តិដ្ឋំ ចរំ...បេ... អធិដ្ឋេយ្យា’’តិ។

តស្សត្ថោ ឯវមេតំ មេត្តំ មានសំ ភាវេន្តោ សោ ‘‘និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយា’’តិអាទីសុ វិយ ឥរិយាបថនិយមំ អកត្វា យថាសុខំ អញ្ញតរញ្ញតរឥរិយាបថ-ពាធនវិនោទនំ ករោន្តោ តិដ្ឋំ វា ចរំ វា និសិន្នោ វា សយានោ វា យាវតា វិគតមិទ្ធោ អស្ស, អថ ឯតំ មេត្តាឈានសតឹ អធិដ្ឋេយ្យ។

អថ វា ឯវំ មេត្តាភាវនាយ វឌ្ឍនំ ទស្សេត្វា ឥទានិ វសីភាវំ ទស្សេន្តោ អាហ ‘‘តិដ្ឋំ ចរ’’ន្តិ។ វសិប្បត្តោ ហិ តិដ្ឋំ វា ចរំ វា និសិន្នោ វា សយានោ វា យាវតា ឥរិយាបថេន ឯតំ មេត្តាឈានសតឹ អធិដ្ឋាតុកាមោ ហោតិ, អថ វា តិដ្ឋំ វា ចរំ វា...បេ... សយានោ វាតិ ន តស្ស ឋានាទីនិ អន្តរាយករានិ ហោន្តិ, អបិច ខោ យាវតា ឯតំ មេត្តាឈានសតឹ អធិដ្ឋាតុកាមោ ហោ

តិ, តាវតា វិគតមិទ្ធោ ហុត្វា អធិដ្ឋាតិ, នត្ថិ តស្ស តត្ថ ទន្ធាយិតត្តំ. តេនាហ "តិដ្ឋំ ចរំ និសិន្នោ វ, សយានោ យាវតាស្ស វិតមិទ្ធោ ។ ឯតំ សតឹ អធិដ្ឋេយ្យា"តិ។

តស្សាយមធិប្បាយោ យំ តំ "មេត្តញ្ច សព្វលោកស្មិ, មានសំ ភាវយេ"តិ វុត្តំ, តំ យថា ភាវេយ្យ, យថា ឋានាទីសុ យាវតា ឥរិយាបថេន ឋានាទីនិ វា អនាទិយិត្វា យាវតា ឯតំ មេត្តាឈានសតឹ អធិដ្ឋាតុកាមោ អស្ស, តាវតា វិគតមិទ្ធោវ ហុត្វា ឯតំ សតឹ អធិដ្ឋេ-យ្យាតិ។

ឯវំ មេត្តាភាវនាយ វសីភាវំ ទស្សេន្តោ "ឯតំ សតឹ អធិដ្ឋេយ្យា"តិ តស្មិំ មេត្តាវិហារេ និយោជេត្វា ឥទានិ តំ វិហារំ ថុនន្តោ អាហ "ព្រហ្មមេតំ វិហារមិធមាហូ"តិ។

តស្សត្ថោ យ្វាយំ "សុខិនោ វា ខេមិនោ វា ហោន្តូ"តិអាទិ កត្វា យាវ "ឯតំ សតឹ អធិដ្ឋេយ្យា"តិ វណ្ណិតោ មេត្តាវិហារោ។ ឯតំ ចតូសុ ទិព្ពព្រហ្មអរិយឥរិយាបថវិហារេសុ និទ្ទោសត្តា អត្តនោបិ បរេសម្បិ អត្ថករត្តា ច ឥធ អរិយស្ស ធម្មវិនយេ ព្រហ្មវិហារមាហុ សេដ្ឋវិហារមាហូតិ, យតោ សតតំ សមិតំ អព្វោកិណ្ណំ តិដ្ឋំ ចរំ និសិន្នោ វា សយានោ វា យាវតាស្ស វិគតមិទ្ធោ, ឯតំ សតឹ អធិដ្ឋេយ្យាតិ។

## ទសមគាថាវណ្ណនា

១០.ឯវំ ភគវា តេសំ ភិក្ខូនំ នានប្បការតោ មេត្តាភាវនំ ទស្សេត្វា ឥទានិ យស្មា មេត្តា សត្តារម្មណត្តា អត្តទិដ្ឋិយា អាសន្នា ហោតិ, តស្មា ទិដ្ឋិគហននិសេធនមុខេន តេសំ ភិក្ខូនំ តទេវ មេត្តាឈានំ បាទកំ កត្វា អរិយភូមិប្បត្តិំ ទស្សេន្តោ "ទិដ្ឋិញ្ច អនុបគ្គម្មា"តិ ឥមាយ គាថាយ ទេសនំ សមាបេសិ។

តស្សត្ថោ យ្វាយំ "ព្រហ្មមេតំ វិហារមិធមាហូ"តិ សំវណ្ណិតោ មេត្តាឈានវិហារោ, តតោ វុដ្ឋាយ យេ តត្ថ វិតក្កវិចារាទយោ ធម្មា, តេ តេសញ្ច វត្ថាទិអនុសារេន រូបធម្មេ បរិគ្គហេត្វា ឥមិនា នាមរូបបរិច្ឆេទេន "សុទ្ធសង្ខារបុញ្ជោយំ, នយិធ សត្តូបលព្ភតី"តិ ឯវំ ទិដ្ឋិញ្ច អនុបគ្គម្ម អនុបុព្វេន លោកុត្តរសីលេន សីលវា ហុត្វា លោកុត្តរសីលសម្បយុត្តេ- នេវ

សោតាបត្តិមគ្គសម្មាទិដ្ឋិសញ្ញិតេន ទស្សនេន សម្បន្នោ, តតោ បរំ យោបាយំ វត្ថុកាមេសុ គេធោ កិលេសកាមោ អប្បហីនោ ហោតិ, តម្បិ សកទាគាមិអនាគាមិមគ្គេហិ តនុភាវេន អនវសេសប្បហានេន ច កាមេសុ គេធំ វិនេយ្យ វិនយិត្វា វូបសមេត្វា ន ហិ ជាតុ គព្ភសេយ្យំ បុន រេតិ ឯកំសេនេវ បុន គព្ភសេយ្យំ ន ឯតិ។ សុទ្ធាវាសេសុ និព្វត្តិត្វា តត្ថេវ អរហត្តំ បាបុណិត្វា បរិនិព្វាតីតិ។

ឯវំ ភគវា ទេសនំ សមាបេត្វា តេ ភិក្ខូ អាហ “គច្ឆថ, ភិក្ខវេ, តស្មឹយេវ វនសណ្ឌេ វិ-ហរថ, ឥមញ្ច សុត្តំ មាសស្ស អដ្ឋសុ ធម្មស្សវនទិវសេសុ គណ្ឌឹ អាកោដេត្វា ឧស្សារេថ, ធម្មកថំ ករោថ សាកច្ឆថ អនុមោទថ, ឥទមេវ កម្មដ្ឋានំ អាសេវថ ភាវេថ ពហុលីករោថ, តេបិ វោ អមនុស្សា តំ ភេរវារម្មណំ ន ទស្សេស្សន្តិ, អញ្ញទត្ថុ អត្ថកាមា ហិតកាមា ភវិស្ស-ន្តី”តិ។ តេ “សាធូ”តិ ភគវតោ បដិស្សុណិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថ គន្ត្វា តថា អកំសុ។ ទេវតាយោ ច “ភទន្តា អម្ហាកំ អត្ថកាមា ហិតកាមា”តិ បីតិសោមនស្សជាតា ហុត្វា សយមេវ សេនាសនំ សម្មជ្ជន្តិ, ឧណ្ហោទកំ បដិយាទេន្តិ, បិដ្ឋិបរិ -កម្មំ បាទបរិកម្មំ ករោន្តិ, អារក្ខំ សំវិទហន្តិ ។ តេបិ ភិក្ខូ តមេវ មេត្តំ ភាវេត្វា តមេវ ច បាទកំ កត្វា វិបស្សនំ អារភិត្វា សព្វេ តស្មឹយេវ អន្តោតេមាសេ អគ្គផលំ អរហត្តំ បាបុណិត្វា មហាបវារណាយ វិសុទ្ធិបវារណំ បវារេសុន្តិ ។

ឯវម្បិ អត្ថកុសលេន តថាគតេន,
ធម្មិស្សរេន កថិតំ ករណីយមត្ថំ;
កត្វានុភុយ្យ បរមំ ហទយស្ស សន្តឹ,
សន្តំ បទំ អភិសមេន្តិ សមត្តបញ្ញា ។
តស្មា ហិ តំ អមតមព្ភុតមរិយកន្តំ,

សន្តំ បទំ អភិសមេច្ច វិហរិតុកាមោ;

វិញ្ញូ ជនោ វិមលសីលសមាធិបញ្ញា-

ភេទំ ករេយ្យ សតតំ ករណីយមត្ថិ។

បរមត្ថជោតិកាយ ខុទ្ទកបាឋ-អដ្ឋកថាយ

មេត្តសុត្តវណ្ណនា និដ្ឋិតា។

# ៩-មេត្តសុត្តវណ្ណនា

## ពណ៌នាអំពីមេត្តសូត្រ

## និក្ខេបប្បយោជន៍

### ប្រយោជន៍នៃការតាំងសូត្រ

ឥឡូវនេះ ដល់លំដាប់ការពណ៌នា សេចក្ដីរបស់មេត្តសូត្រ ដែលលើកមកសម្ដែងបន្ទាប់អំពី និធិកណ្ឌសូត្រ ។ ក្នុងទីនេះ ខ្ញុំនឹងពោល ប្រយោជន៍របស់ការតាំងមេត្តសូត្រនោះហើយ តអំពីនោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនោះ ថា មេត្តសូត្រនោះ អ្នកណាពោល ពោលកាលណា ពោលទីណា និងពោល ព្រោះហេតុណាជម្រះនិទានហើយទើបនឹងធ្វើការពណ៌នាសេចក្ដីរបស់មេត្តសូត្រនោះ ។

ក្នុងមេត្តសូត្រនោះ ព្រោះហេតុដែលទ្រង់ត្រាស់ បុញ្ញសម្បទាមានទានសីលជាដើមដោយនិធិកណ្ឌសូត្រ ។ កាលបុគ្គលធ្វើមេត្តាក្នុងសត្វទាំងឡាយ បុញ្ញសម្បទានោះ រមែងមានផលច្រើន ហួតដល់ប្រាថ្នាឱ្យចាក់ធ្លុះពុទ្ធភូមិបានដូច្នោះ ទើបខ្ញុំលើកមេត្តសូត្រ ឡើងតាំងទុកក្នុងទីនេះ ដើម្បីសម្ដែងថា មេត្តាជាឧបការៈដល់បុញ្ញសម្បទានោះ ឬព្រោះហេតុ ដែលខ្ញុំកាលសម្ដែងកម្មដ្ឋាន ដែលលះទោសៈដោយទ្វត្តិង្សាការៈ សម្រាប់ជនទាំងឡាយអ្នកគោរពព្រះពុទ្ធសាសនា ដោយសរណៈ ហើយតាំងនៅក្នុងសីល ដោយសិក្ខាបទ ទាំងឡាយនឹងអាចលះមោហៈដោយកុមារបញ្ហា ទើបសម្ដែងថា ការប្រព្រឹត្តិសរណៈជាដើមនោះ ជាមង្គល និងរក្សាខ្លួនឯង ដោយមង្គលសូត្រ សម្ដែងការរក្សាអ្នកដទៃដែលសមដល់មង្គលនោះ ដោយរតនសូត្រ សម្ដែងការឃើញភូតពួកខ្លះ បណ្ដាភូតទាំងឡាយ ដែល

ពោលទុកក្នុងរតនសូត្រ និងសេចក្តីវិបត្តិរបស់ពួកជន ដែលប្រមាទក្នុងបុញ្ញសម្បត្តិ ដូចដែលពោលហើយក្នុងតិរោកុឌ្ឌសូត្រ និងសម្តែងសម្បត្តិ ដែលជាបដិបក្ខចំពោះវិបត្តិ ដែលពោលទុកក្នុងតិរោកុឌ្ឌសូត្រ ដោយនិធិកណ្ឌសូត្រ តែនៅមិនបាន សម្តែងកម្មដ្ឋាន ដែលអាចលះទោសៈនោះ ព្រោះដូច្នោះ ទើបខ្ញុំលើកមេត្តសូត្រនេះឡើងតាំងក្នុងទីនេះ ដើម្បីសម្តែងកម្មដ្ឋាន ជាគ្រឿងលះបង់នូវទោសៈ ។ កាលបើដូច្នេះ ខុទ្ទកបាឋ ទើបនឹងបរិបូណ៌ដោយល្អ ។ សេចក្តីដែលពោលមកដូច្នេះ ជាប្រយោជន៍នៃការតាំងមេត្តសូត្រនោះទុកក្នុងទីនេះ ។

## និទានសោធនំ

## ការជម្រះនិទាន

ឥឡូវនេះ ខ្ញុំលើកមាតិកាខាងចុងនេះទុកថា គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា ៖

មេត្តសូត្រនេះ អ្នកណាពោល ពោលកាលណា ពោលទីណានិងពោល ព្រោះហេតុណា ខ្ញុំជម្រះនិទានហើយ ទើបនឹងធ្វើការពណ៌នាសេចក្តីនៃមេត្តសូត្រនោះដូច្នេះ ។

ក្នុងមាតិកាចុងសេចក្តីនោះ គប្បីបង្ហាញបទទាំងនេះ និងការជម្រះនិទាន ដោយសង្ខេបយ៉ាងនេះមុនថា៖ មេត្តសូត្រនេះព្រះដ៏មានព្រះភាគមួយព្រះអង្គគត់

ប៉ុណ្ណោះ បានត្រាស់សម្តែង សាវ័កជាដើមមិនបានពោលទេ ។ តែថាកាលណា ភិក្ខុទាំងឡាយ ត្រូវទេវតាទាំងឡាយនៅក្នុំហេមវន្តបន្លាច ទើបនាំគ្នាមកគាល់ព្រះមានព្រះភាគ កាលនោះព្រះដ៏ព្រះភាគទើបត្រាស់មេត្តសូត្រនោះ ដើម្បីការពារ និងដើម្បីជាកម្មដ្ឋាន សម្រាប់ភិក្ខុទាំងនោះ ។ ចំណែកសេចក្តីពិស្តារគប្បីជ្រាបយ៉ាងនេះ ។

សម័យមួយ ជិតតិថីចូលចាំព្រះវស្សា ព្រះដ៏មានព្រះភាគប្រថាប់ក្នុងក្រុងសាវត្ថី ។ សម័យនោះ ភិក្ខុទាំងឡាយចេញចាកក្រុងផ្សេងៗមានចំនួនច្រើនទទួលកម្មដ្ឋានក្នុងសំណាក់ព្រះដ៏មានព្រះភាគ ហើយមានបំណងទីងចូលចាំវស្សាក្នុងទីនោះៗ ទើបចូលគាល់ព្រះដ៏មានព្រះភាគ ។ បានឮថា សម័យនោះឯងព្រះមានព្រះភាគត្រាស់កម្មដ្ឋានទាំងឡាយ ដែលអនុកូលដល់ចរិតចំនួន ៨៤,០០០ ប្រភេទ ដោយន័យនេះគឺ អសុភកម្មដ្ឋាន ១១ យ៉ាងគឺ អសុភៈមាន វិញ្ញាណ និងមិនមានវិញ្ញាណសម្រាប់មនុស្សរាគចរិត កម្មដ្ឋានមានមេត្តាកម្មដ្ឋានជាដើម ៤ យ៉ាងសម្រាប់មនុស្សទោសចរិត កម្មដ្ឋានមានមរណស្សតិកម្មដ្ឋានជាដើម សម្រាប់មនុស្សមោហៈចរិត កម្មដ្ឋានមានអនាបានស្សតិ និងបឋវីកសិណជាដើម សម្រាប់មនុស្សវិតក្កចរិត កម្មដ្ឋានមានពុទ្ធានុស្សតិកម្មដ្ឋានជាដើម សម្រាប់មនុស្សសទ្ធា-ចរិត កម្មដ្ឋានមានចតុធាតុវវត្ថានកម្មដ្ឋានជាដើម សម្រាប់មនុស្ស ពុទ្ធិចរិត ។

លំដាប់នោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋាន ក្នុងសំណាក់ព្រះមានព្រះភាគ កំពុងស្វែងរកសេនាសនៈ ជាទីសប្បាយ និងគោចរគ្រាម ដើរទៅតាមលំដាប់ បានជួបភ្នំផាំងសិលា ស្រដៀងមណីពណ៌ក្រហមប្រដាប់ ដោយដងព្រៃពណ៌ខៀវ មានម្លប់ត្រឈឹងត្រឈៃត្រជាក់ មានភូមិពាសពេញ ដោយដីខ្សាច់ហាក់បីដូចផែនកែវមុក្តា ព័ទ្ធដោយជលាស័យ ដែលបរិសុទ្ធល្អត្រជាក់ជាប់ជាមួយព្រៃហេមវន្ត ក្នុងបច្ចន្តប្រទេស ។ ភិក្ខុទាំងនោះ ស្នាក់នៅមួយយប់ក្នុងទីនោះ កាលរាត្រីកន្លងទៅហើយ ពេលព្រឹកធ្វើ សរីរៈកិច្ចហើយ ក៏នាំគ្នាចូលទៅបិណ្ឌបាត ទៅភូមិមួយកន្លែងជិតទីនុ៎ះឯង ។ ភូមិប្រកបដោយត្រកូល ១.០០០ ត្រកូល ដែលអាស្រ័យនៅកុះករក្នុងភូមិនោះ មនុស្សទាំងឡាយ អ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា ពួកគេឃើញភិក្ខុទាំងឡាយប៉ុណ្ណោះ ក៏កើតបីតិសោមនស្ស ព្រោះការឃើញបព្វជិត ក្នុងបច្ចន្តប្រទេសរកបានដោយលំបាក និមន្តភិក្ខុទាំងនោះ ឱ្យឆាន់ហើយ ក៏អង្វរសូមថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះ រហូតអស់ត្រីមាសចុះ" ហើយជួយគ្នាសាងកុដិ សម្រាប់ធ្វើសេចក្តីព្យាយាម ៥០០ ខ្នង ចាត់ចែងគ្រឿងឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ក្អមទឹកឆាន់ ទឹកប្រើប្រាស់ជាដើមក្នុងទីនោះ ។

ថ្ងៃព្រឹកឡើង ភិក្ខុទាំងឡាយចូលទៅបិណ្ឌបាតនៅភូមិដទៃ ។ ក្នុងភូមិសូម្បីនោះ មនុស្សទាំងឡាយ ក៏និយាយ ដើម្បីទំនុកបម្រុងពួកភិក្ខុយ៉ាងនោះដូចគ្នា អង្វរ

ឱ្យទៅចាំវស្សា ។ ភិក្ខុទាំងឡាយ ទទួលនិមន្តដោយមានលក្ខខណ្ឌថា កាលមិនមានអន្តរាយ (អាត្មានឹងទៅ) ហើយនាំគ្នាចូលទៅនៅផងព្រៃនោះ ជាអ្នកប្រារព្ធ សេចក្តីព្យាយាម រហូតអស់យប់ និងថ្ងៃ វាយរគាំង ប្រាប់យាម ជាអ្នកច្រើនទៅ ដោយយោនិសោមនសិការៈ ទើបចូលទៅអង្គុយត្រង់គល់ឈើ ។ រុក្ខទេវតាទាំងឡាយ ត្រូវតេជះរបស់ពួកភិក្ខុ អ្នកមានសីល កម្ចាត់តេជះរបស់ខ្លួនបាត់ហើយ ក៏ចុះអំពីវិមានរបស់ខ្លួនៗនាំពួកកូនៗ ធ្វើដំណើរអំពីទីនោះៗ ។ ប្រៀបដូចកាលព្រះរាជា ឬរាជមហាមាត្យ កាលទៅកាន់ទីនៅរបស់អ្នកភូមិ កាន់យកឱកាសទំនេរក្នុងផ្ទះទាំងឡាយរបស់អ្នកភូមិ អ្នកភូមិក៏ត្រូវចេញចាកភូមិទៅនៅកន្លែងដទៃ ក៏បានតែត្រឹមសម្លឹងមើលទៅឆ្ងាយៗ ដោយសង្ឃឹមថា "កាលណាហ្ន៎ ទើបលោកនឹងចេញទៅ? ទេវតាទាំងឡាយ ត្រូវលះចោលវិមានរបស់ខ្លួនៗ បែកខ្ញែកគ្នា បានតែត្រឹមសម្លឹងមើលពីទៅឆ្ងាយៗដោយសង្ឃឹមថា "កាលណាហ្ន៎ ទើបលោកម្ចាស់ទាំងឡាយនិមន្តទៅ" ក៏យ៉ាងនោះដូចគ្នា ។ តាំងតែពីនោះ ទេវតាទាំងឡាយ ក៏រួមគំនិតគិតគ្នាយ៉ាងនេះថា "ភិក្ខុទាំងឡាយចូលវស្សាដំបូងហើយនឹងនៅរហូតដល់ត្រីមាសពិតប្រាកដ តែពួកយើងមិនអាចនឹងនាំពួកក្មេង ទៅយ៉ាងលំបាកបាន" ណ្ហើយចុះ ពួកយើងនឹងសម្តែងអារម្មណ៍ ដែលគួរខ្លាចដល់ភិក្ខុទាំងឡាយ ។ ទេវតាទាំងនោះ ទើបនិមិត្តរូបយក្ស ដែលគួរខ្លាចឈរនៅខាងមុខៗ វេលាភិក្ខុទាំងឡាយធ្វើសមណធម៌រហូតដល់កណ្តាលយប់ និងធ្វើសំឡេង

គួរឱ្យភ័យខ្លាច ។ ភិក្ខុទាំងឡាយ ព្រោះឃើញរូបទាំងនោះ ក៏មានសម្បុរស្លេកស្លាំង និងកើតជារោគស្ពមលឿង ។ ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបមិនអាចធ្វើចិត្តឱ្យមានអារម្មណ៍តែមួយបាន កាលចិត្តមិនមានអារម្មណ៍តែមួយ ស្អុតចិត្តរឿយៗ ព្រោះខ្លាចសតិរបស់ភិក្ខុពួកនោះ ក៏វង្វេងមិនច្បាស់ តាំងអំពីនោះ អារម្មណ៍ដែលស្អុយៗ ក៏ជួបជួនដល់ភិក្ខុពួកនោះ ដែលមានសតិវង្វេងវង្វាន់ ហើយ ។ ខួរក្បាលរបស់ភិក្ខុពួកនោះ ក៏ដូចត្រូវក្លិនស្អុយនោះកៀបសង្កត់រោគឈឺសីសៈក៏កើតឡើងយ៉ាងធ្ងន់ ។ ភិក្ខុទាំងនោះ ក៏មិនព្រមប្រាប់រឿងនោះដល់គ្នា នឹងគ្នា ។

តមកថ្ងៃមួយ កាលភិក្ខុគ្រប់រូបប្រជុំគ្នាក្នុងវេលា ទំនុកបម្រុងព្រះសង្ឃត្ថេរ ។ ព្រះសង្ឃត្ថេរក៏សួរថា អ្នកមានអាយុ កាលពួកលោកចូលទៅក្នុងដងព្រៃនោះ ស្បែកពណ៌សម្បុរបរិសុទ្ធផូរផង់យ៉ាងក្រៃលែង នៅ ២-៣ ថ្ងៃ ទាំងឥន្ទ្រិយក៏ស្រស់ថ្លា តែឥឡូវនេះ ក្នុងទីនេះ ពួកលោកស្គមស្បែកស្លេកស្លាំងកើតជារោគលឿង ក្នុងទីនេះពួកលោកមិន សប្បាយឬ ។ លំដាប់នោះ ភិក្ខុមួយរូបពោលថា បពិត្រលោកម្ចាស់ វេលាយប់មិញនេះ ខ្ញុំឃើញ និងបានឮអារម្មណ៍ដែលគួរខ្លាចយ៉ាងនេះៗ ស្រូបតែក្លិន ដូច្នេះ ព្រោះហេតុនោះ ចិត្តរបស់ខ្ញុំទើបមិនតាំងមាំជាសមាធិ ។ ភិក្ខុទាំងនោះគ្រប់រូប ទើបនាំគ្នាប្រាប់រឿងនោះ ដោយឧបាយនេះដូចគ្នា ។ ព្រះសង្ឃត្ថេរពោលថា អ្នកមានអាយុ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តការចូលចាំ

វស្សាទុក ២ យ៉ាង ក៏សេនាសនៈមិនជាទីសប្បាយដល់ពួកយើង មកចុះ អ្នកមាន
អាយុពួកយើងនឹងនាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគ ទូលសួរនូវសេនាសនៈ
ដែលជាទីសប្បាយដទៃៗ ភិក្ខុទាំងនោះ ទទួលពាក្យព្រះថេរៈថា ករុណាលោក
ម្ចាស់ គ្រប់រូបក៏ប្រមូល បិទបាំងសេនាសនៈ កាន់បាត្រចីវរ មិនប្រាប់ដល់
នរណាៗ ក្នុងត្រកូលទាំងឡាយ នាំគ្នាចារិកទៅកាន់ក្រុងសាវត្ថី ក៏ដល់ក្រុង-
សាវត្ថីតាមលំដាប់ហើយ ក៏នាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ។

ព្រះដ៏មានព្រះភាគ ទ្រង់ឃើញភិក្ខុទាំងនោះទើបត្រាស់ថា ម្នាលភិក្ខុទាំង-
ឡាយ តថាគតបញ្ញត្តសិក្ខាបទទុកថា ភិក្ខុមិនគប្បីត្រាច់ចារិកទៅខាងក្នុងវស្សា
ហេតុអ្វីពួក លោកទើបចារិកទៅ ។ ភិក្ខុពួកនោះ ទើបក្រាប ទូលរឿងទាំងអស់
ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់នឹកគិត ក៏ទ្រង់មិនឃើញ
សេនាសនៈ ដែលជាទីសប្បាយដទៃសម្រាប់ភិក្ខុទាំងនោះ ទាំងជម្ពូទ្វីប ដោយទី
បំផុត សូម្បីត្រឹមតែតាំងមានជើង ៤ ដូច្នេះ ទើបត្រាស់ប្រាប់ភិក្ខុទាំងនោះថា
"ម្នាលភិក្ខុទាំងឡាយ សេនាសនៈដែលជាទីសប្បាយដទៃសម្រាប់អ្នកទាំងឡាយ
មិនមាន អ្នកទាំងឡាយនៅក្នុងទីនោះៗឯង នឹងបន្ទុះធម៌ជាទីអស់អាសវៈ ទៅ
ចុះភិក្ខុទាំងឡាយ អ្នកទាំងឡាយទៅអាស្រ័យសេនាសនៈនោះទុំឯងនៅចុះ តែ

បើថាអ្នកទាំងឡាយប្រាថ្នាការមិនមានភ័យអំពីទេវតាទាំងឡាយ ក៏ចូរនាំគ្នារៀនព្រះបរិត្តនេះ" ។ ព្រោះថាព្រះបរិត្តនេះ នឹងបានជាគ្រឿងការពារ ហើយជាកម្មដ្ឋានសម្រាប់អ្នកទាំងឡាយ ដូច្នេះហើយទើបទ្រង់ត្រាស់ព្រះសូត្រនេះ ។

តែអាចារ្យពួកដទៃទៀតពោលថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ទៅចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូលទៅអាស្រ័យសេនាសនៈនុ៎ះឯងទៅចុះ ហើយទើបត្រាស់ថា ភិក្ខុអ្នកនៅព្រៃគួរធ្វើនូវនឹងការរក្សា" ។ រក្សាយ៉ាងណា រក្សាយ៉ាងនេះគឺ ផ្សាយមេត្តា ២ ពេលគឺ ពេលល្ងាច និងពេលព្រឹក ចម្រើនព្រះបរិត្ត ២ ពេល ចម្រើនអសុភៈ ២ ពេល ចម្រើនមរណស្សតិ ២ ពេល និងនឹកដល់មហាសំវេគវត្ថុ ៨ ។ ឈ្មោះថា មហាសំវេគវត្ថុ ៨ គឺ ជាតិ ជរា ព្យាធិ មរណៈ និងអបាយទុក្ខ ៤ ។ ន័យមួយទៀត ជាតិជរាព្យាធិមរណៈ ៤ អបាយទុក្ខជាទី ៥ ទុក្ខមានវដ្តជាមូលក្នុងអតីត ១ ទុក្ខមានវដ្តជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រាប់ការរក្សាយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ព្រះសូត្រនេះដើម្បីជាមេត្តា ដើម្បីជាព្រះបរិត្ត និងដើម្បីជាឈាន ដែលជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។ គប្បី

ជ្រាបការពន្យល់ បទទាំងនេះថា **យេន វុត្តំ យទា យត្ថ យស្មា ចេ** និងការជម្រះនិទានដោយពិស្តារយ៉ាងនេះ ។

មាតិកាចុងសេចក្តីនោះណា ខ្ញុំតាំងទុកថា យេន វុត្តំ យទា យត្ថ យស្មា ចេតេស ធីបនា និទានំ សោធយិត្វា មាតិកាចុងសេចក្តីនោះ ដែលខ្ញុំពោលពិស្តារហើយដោយអាការៈទាំងពួងដោយកថាប្រមាណត្រឹមនេះ ។

## បឋមគាថាវណ្ណនា

### ពណ៌នាគាថាទី ១

ឥឡូវនេះ នឹងផ្តើមពណ៌នាសេចក្តីនៃព្រះសូត្រនោះ ដែលធ្វើការជម្រះនិទានហើយយ៉ាងនេះ ។ ព្រោះពោលទុកថា ទើបនឹងធ្វើការពណ៌នា សេចក្តីនៃព្រះសូត្រនោះដូច្នោះ ។ ក្នុងគាថានោះ នឹងផ្តើមពណ៌នាបទនៃគាថានេះ ថា **ករណីយមត្ថកុសលេន** មុនដូច្នេះ ។ បទថា **ករណីយំ** ប្រែថា គប្បីធ្វើ អធិប្បាយថា គួរដល់ការធ្វើបដិបទា ។ ឈ្មោះថា អត្ថ ឬប្រយោជន៍គាំទ្រយ៉ាងណាមួយ ប្រយោជន៍គាំទ្រនោះទាំងអស់ លោកហៅថា អត្ថ ព្រោះមិនមានកិលេសដូចសត្រូវ ឈ្មោះថា **ករណីយៈ** ព្រោះដែលបុគ្គលគប្បីចូលដល់ ។ ជាអ្នកឆ្លាតក្នុងប្រយោជន៍ ឈ្មោះថា អត្ថកុសលេន លោកអធិប្បាយថា ជាអ្នកវាងវៃក្នុង

ប្រយោជន៍ ។ បទថា **យំ** ជាបឋមាវិភត្តិសម្តែងមិនជាក់លាក់ ។ បទថា **តំ** ជាទុតិយាវិភត្តិសម្តែងសេចក្តីជាក់លាក់ ។ ឬបទថា **យំ តំ** សូម្បីទាំងពីរ ជាបឋមា-វិភត្តិ ។ បទថា **សន្តំ បទំ** ជាទុតិយាវិភត្តិ ។ បណ្តាបទទាំងពីរនោះ ដែលឈ្មោះថា សន្តំ ព្រោះជាលក្ខណៈ បទំ ព្រោះបុគ្គលគប្បីដល់ ពាក្យនេះជា ឈ្មោះរបស់ព្រះនិព្វាន ។បទថា អភិសមេច្ច ប្រែថា បន្ទុះហើយ ។ អ្នកណារមែងអាចហេតុនោះ អ្នកនោះ ឈ្មោះថា សក្កោ អ្នកអាច លោកអធិប្បាយថា អ្នកប្រាថ្នាអ្នកអង់អាច ។ បទថា ឧជូ បានដល់ អ្នកប្រកបដោយសេចក្តីត្រង់ ។ អ្នកណាត្រង់ ដោយល្អ ហេតុនោះ អ្នកនោះឈ្មោះ **សុហុជូ** អ្នកត្រង់ដោយល្អ ។ សេចក្តីថា ងាយស្រួលមានក្នុងអ្នកនោះ ហេតុនោះ អ្នកនោះ ឈ្មោះថា សុវចោ អ្នកងាយស្រួល ។ បទថា អស្ស ប្រែថា គប្បីមានគប្បីកើត ។ បទថា មុទុ បានដល់ អ្នកប្រកបដោយការទន់ភ្លន់ ។ អ្នកណាមិនមានអតិមានៈ ហេតុនោះ អ្នកនោះ ឈ្មោះថា **អនតិមានី** មិនមានអតិមានៈ ។

ចំណែកការពណ៌នាសេចក្តីក្នុងគាថាទី ១ ដូច្នេះ ៖

វិនិច្ឆ័យក្នុងបទថា ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច នេះមុន ករណីយក៏មាន អករណីយក៏មាន ។ បណ្តាពីរយ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា ករណីយៈ ។ សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ

អាជីវវិបត្តិ ដូចពោលមកយ៉ាងនេះជាដើម ឈ្មោះថា **អករណីយៈ** ៥ យ៉ាងទៀត អត្តកោសលក៏មាន អនត្តកោសលក៏មាន ៥ បណ្តា ២ យ៉ាងនោះ កុលបុត្របួសក្នុងព្រះសាសនានេះ មិនប្រកបខ្លួនទុកដោយប្រពៃជាអ្នកមានសីលដាច់ អាស្រ័យ **អនេសនៈ**(ការស្វែងរកមិនសមគួរ) ២១ យ៉ាងដើម្បីចិញ្ចឹមជីវិត គឺ

១- វេឡុទានំ = ឱ្យឫស្សី

២- បត្តទានំ = ឱ្យស្លឹកឈើ

៣- បុប្ផទានំ = ឱ្យផ្កាឈើ

៤- ផលទានំ = ឱ្យផ្លែឈើ

៥- ទន្តកដ្ឋទានំ = ឱ្យឈើជម្រះធ្មេញ

៦- មុខោទកទានំ = ឱ្យទឹកលាងមុខ

៧- សិនានទានំ = ឱ្យទឹកងូត

៨- ចុណ្ណទានំ = ឱ្យម្សៅលាបខ្លួន

៩- មត្តិកាទានំ = ឱ្យដីដុសខ្លួន

១០- ចាដុកម្យតំ = ផ្គាប់ផ្គុន

**១១-មុគ្គសូប្យតំ** ▪ *និយាយពិតលាយកុហក(ដូចបបរសណ្តែកបាយ)*

**១២-ចាដុកម្យតំ** ▪ *ចិញ្ចឹមកូនឱ្យគេ*

**១៣-ជង្ឃបេសនិកំ** ▪ *ទទួលបម្រើគ្រហស្ថ*

**១៤-វេជ្ជកម្មំ** ▪ *ធ្វើខ្លួនជាពេទ្យព្យាបាល*

**១៥-ទូតកម្មំ** ▪ *ធ្វើខ្លួនជាទូត*

**១៦-បហិណគមនំ** ▪ *ទទួលបញ្ជូនសារគ្រហស្ថ*

១៧-បិណ្ឌបដិបិណ្ឌំ = *ការឱ្យចង្ហាន់បិណ្ឌបាតដល់ត្រកូល*

**១៨-ទានានុប្បទានំ** ▪ *ឱ្យទៅឱ្យមក*

១៩-វត្ថុវិជ្ជំ =*ធ្វើជាហោរមើលផ្ទៃដី*

២០-នក្ខត្តវិជ្ជំ =*ធ្វើជាគ្រូមើលនក្ខត្តឫក្ស*

២១-អង្គវិជ្ជនំ =*ធ្វើជាគ្រូមើលលក្ខណៈ*

*មិនប្រព្រឹត្តអគោចរៈ ៦ យ៉ាងគឺ*

១-វេសិយាគោចរោ =*ត្រាច់ទៅកាន់សម្នាក់ស្ត្រីពេស្យា*

២-វិធវគោចរោ = *ត្រាច់ទៅកាន់សម្នាក់ស្ត្រីមេម៉ាយ*

៣-ចុល្លកុមារិកគោចរេ =ត្រាច់ទៅកាន់សម្នាក់ស្ត្រីក្រមុំចាស់

៤-បណ្ឌកគោចរេ =ត្រាច់ទៅកាន់សម្នាក់មនុស្សខ្ទើយ

៥-ភិក្ខុនីគោចរេ =ត្រាច់ទៅកាន់សម្នាក់នាងភិក្ខុនី

៦-បានាគារគោចរេ =ត្រាច់ទៅកាន់រោងស្រា ។

ទិនការសេពគប់ស្និទ្ធស្នាលជាមួយគ្រហស្ថផង ព្រះរាជាផង ព្រះរាជអាមាត្យរបស់ព្រះរាជាផង តិរ្ថិយផង សាវ័ករបស់តិរ្ថិយផង ដោយការសេពគប់ស្និទ្ធស្នាល ដែលមិនសមគួរ ។ ការសេពគប់ចូលចិត្តត្រកូលដែលមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា មិនដូចជាអណ្តូងទឹក ជេរ ទិនស្តីបន្ទោស សង្ស័យតែប្រយោជន៍ មិនគាំទ្រ មិនប្រព្រឹត្តិដើម្បីសេចក្តីសុខសាន្ត មិនដើម្បីប្រោសចាកយោគៈ ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា កុលបុត្រនោះឈ្មោះថា អ្នកឈ្លាសក្នុងវត្តដែលមិនមានប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាបួសក្នុងព្រះសាសនានេះ ប្រកបនូវដោយពេញចិត្តលះអនេសនៈប្រាថ្នាតែទីងតាំងទៅក្នុងចតុបារិសុទ្ធិសីល បំពេញបាតិមោក្ខសំ-វរសីល ដោយសទ្ធាជាសំខាន់ បំពេញឥន្ទ្រិយសំវរសីល ដោយសតិជាសំខាន់ បំពេញអាជីវបារិសុទ្ធិសីល ដោយសេចក្តីព្យាយាមជាសំខាន់ បំពេញនូវបច្ចយ-សន្និស្សិតសីល ដោយបញ្ញាជាសំខាន់ កុលបុត្រនោះឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាជម្រះបាតិមោក្ខសំវរសីល ដោយជម្រះអាបត្តិ ៧ កង ជម្រះឥន្ទ្រិយសំវរសីល ដោយមិនឱ្យអភិជ្ឈាជាដើមកើតក្នុងអារម្មណ៍ ដែលប៉ះខ្ទប់ក្នុងទ្វារ ៦ ជម្រះអាជីវបារិសុទ្ធិសីល ដោយវៀរចាកអនេសនៈ និងប្រើប្រាស់បច្ច័យដែលវិញ្ញូជន ព្រះពុទ្ធ និងពុទ្ធសាវកសរសើរហើយ ជម្រះការប្រើប្រាស់បច្ច័យ ដោយការពិចារណាបច្ច័យតាមដែលពោលហើយ និងជម្រះការសម្បជញ្ញៈ ដោយការពិចារណានូវសាត្ថកសម្បជញ្ញៈជាដើម ក្នុងការផ្លាស់ប្តូរឥរិយាបថទាំង ៤ សូម្បីកុលបុត្រនោះ ក៏ឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាដឹងថា សំពត់កខ្វក់អាស្រ័យទឹកអំបិល ក៏ធ្វើឱ្យស្អាតបាន កញ្ចក់អាស្រ័យផេះក៏ធ្វើឱ្យស្អាតបាន មាសអាស្រ័យឡសម្រាប់ដុតរំលាយលោហធាតុធ្វើឱ្យបរិសុទ្ធបាន យ៉ាងណា សីលអាស្រ័យញាណ(បញ្ញា) ក៏ធ្វើឱ្យបរិសុទ្ធបានយ៉ាងនោះ ហើយជម្រះដោយទឹកគឺញាណ ក៏ធ្វើសីលឱ្យបរិសុទ្ធបាន ។ ប្រៀបដូចសត្វត្រដេវរ៉ិចរក្សាពង សត្វចាមរីរក្សារោមកន្ទុយ ស្ត្រីមានបុត្រតែមួយ រក្សាបុត្រតែមួយរបស់ខ្លួន បុរសអ្នកមានភ្នែកតែម្ខាងរក្សាភ្នែកតែម្ខាងនោះទុកយ៉ាងណា កុលបុត្រអ្នកមិនប្រមាទយ៉ាងក្រៃលែង ក៏រក្សាសីលក្ខន្ធរបស់ខ្លួនក៏យ៉ាងនោះ គេពិចារណាទាំងព្រឹកល្ងាច ក៏មិនឃើញទោសសូម្បីប្រមាណតិច សូម្បីកុលបុត្រនោះ ក៏ឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាតាំងនៅក្នុងសីល ដោយមិនធ្វើសេចក្តីក្តៅក្រហាយ

រមែងកាន់យកបដិបទា ជាគ្រឿងសង្កត់សង្កិននូវកិលេស ។ ការកាន់យកបដិបទានោះហើយរមែងធ្វើបរិកម្មក្នុងកសិណ កាលធ្វើបរិកម្មហើយ រមែងញ៉ាំងសមាបត្តិទាំងឡាយឱ្យកើត ។ សូម្បីកុលបុត្រនោះ ក៏ឈ្មោះថា អ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត កុលបុត្រណាចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយ រមែងចាក់ធ្លុះព្រះអរហត្ត កុលបុត្រនេះជាកំពូលអ្នកឈ្លាសក្នុងប្រយោជន៍ ។ កុលបុត្រនេះ ជាអ្នកឈ្លាសក្នុងប្រយោជន៍ ដែលលោកសរសើរហើយ ដោយត្រឹមតែការតាំងនៅក្នុងសីល ដែលមិនមានសេចក្ដីក្ដៅក្រហាយ ឬដោយត្រឹមតែការកាន់យកនូវបដិបទា ជាគ្រឿងសង្កត់សង្កិននូវកិលេស កុលបុត្រនោះ លោកបំណងថា អ្នកឈ្លាសក្នុងប្រយោជន៍ក្នុងអត្ថនេះ ។ និងកុលបុត្រទាំងនោះ ក៏មានសភាពយ៉ាងនោះ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់សំដៅដល់កុលបុត្រទាំងនោះ ទើបត្រាស់សម្ដែងដោយទេសនាជាបុគ្គលាធិដ្ឋានប៉ុណ្ណោះ ហើយត្រាស់ទៀតថា ករណីយមត្ថកុសលេន អ្នកឈ្លាសក្នុងប្រយោជន៍គប្បីធ្វើដូច្នេះ ។

តអំពីនោះ កាលកុលបុត្រទាំងនោះ កើតសេចក្ដីសង្ស័យថា កិច្ចដែលត្រូវធ្វើអ្វីខ្លះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា យន្តំ សន្តំ បទំ អភិសមេច្ច ។ ក្នុងពាក្យ នេះមានអធិប្បាយដូច្នេះ៖ កិច្ចឯណា ដែលកុលបុត្រតែងប្រាថ្នាដើម្បីធ្លុះចំពោះ ដោយអំណាចនៃការសម្រេចនូវសន្តិបទ គឺព្រះនិព្វាន កិច្ចនោះ គឺព្រះពុទ្ធ

និងអនុពុទ្ធទាំងឡាយ តែងសរសើរ ។ ក៏ក្នុងពាក្យនេះ គប្បីជ្រាបថា បទថា **យំ** ខ្ញុំពោលទុកខាងដើមបទគាថានេះនោះហើយ រមែងប្រព្រឹត្តទៅដោយអធិការថា **ករណីយំ** គឺ **តំ សន្តំ បទំ អភិសមេច្ច** ។ ព្រោះហេតុតែសេចក្តីនេះ មានបាឋៈដែលនឹងត្រូវផ្តើមពាក្យដ៏សេស ដូច្នេះ ខ្ញុំទើបពោលថា វិហារិតុកាមេន ។

ម្យ៉ាងមួយទៀត ក្នុងពាក្យនេះគប្បីជ្រាបអធិប្បាយយ៉ាងនេះថា បទថា **សន្តំ បទំ អភិសមេច្ច** រមែងប្រព្រឹត្តទៅអធិការថា កិច្ចឯណា ដែលអ្នកបំណងនឹងដឹងបទ គឺព្រះនិព្វានថា សន្តៈ (ស្ងប់) ដោយលោកិយបញ្ញា ដោយការស្តាប់តគ្នាមកជាដើម នឹងចាក់ធ្លុះសន្តិបទ គឺព្រះនិព្វាននោះ កិច្ចនោះ គឺកុលបុត្រគប្បីធ្វើ ។ ន័យមួយទៀត កាលត្រាស់ថា ករណីយមត្ថកុសលេន កាលកុលបុត្រទាំងឡាយនាំគ្នាគិតថាអ្វី ទើបត្រាស់ថា **យន្តំ សន្តំ បទំ អភិសមេច្ច** ន័យនោះគប្បីជ្រាបអធិប្បាយយ៉ាងនេះ កិច្ចណា គឺកុលបុត្រដឹងបទដែលស្ងប់ ដោយលោកិយបញ្ញាហើយ គប្បីធ្វើ គប្បីប្រកប កិច្ចនោះ គឺកុលបុត្រគួរធ្វើ លោកអធិប្បាយថា កិច្ចនោះ គឺកុលបុត្រ គួរដល់ការធ្វើ ។

សួរថា កិច្ចនោះគឺអ្វី ? ឆ្លើយថា កិច្ចអ្វីដទៃក្រៅតែពីការព្រាស់ចាកឧបាយជាគ្រឿងចាក់ធ្លុះនិព្វានបទនោះ គប្បីមាន ។ កិច្ចនោះ ខ្ញុំពោលទុកហើយ

ដោយបទដើមដែលសម្តែងសិក្ខា ៣ ព្រោះអត្ថថា គួរដល់ការធ្វើ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា ក្នុងការពណ៌នាសេចក្តីនៃពាក្យនោះ ខ្ញុំក៏បានពោលទុកហើយថា **ករណីយៈ**ក៏មាន **អករណីយៈ**ក៏មាន ។ បណ្តាពាក្យពីរយ៉ាងនោះ ដោយសង្ខេបសិក្ខា ៣ ឈ្មោះថា **ករណីយៈ** ។ ព្រោះតែទ្រង់សម្តែងទុកសង្ខេបពេក បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះដឹង ភិក្ខុពួកខ្លះមិនដឹង ។ តែកាលត្រាស់កិច្ច ដោយចំពោះយ៉ាងក្រៃលែងដល់ភិក្ខុ អ្នកនៅក្នុងព្រៃគួរធ្វើឱ្យពិស្តារ ដើម្បីឱ្យពួកភិក្ខុដែលមិនដឹងបាន ទើបត្រាស់ក្នុងគាថានេះមុនថា សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុ អនតិមានី ។

លោកអធិប្បាយទុកថាយ៉ាងណា លោកអធិប្បាយថា ភិក្ខុអ្នកនៅព្រៃបំណងចាក់ធ្លុះសន្តិបទ ឬចាក់ធ្លុះសន្តិបទនោះដោយលោកិយបញ្ញា ហើយបដិ-បត្តិដើម្បីចាក់ធ្លុះសន្តិបទនោះ មិនអាល័យក្នុងកាយ និងជីវិត ដោយប្រកបដោយបធានិយង្គៈ ២ និង ៤ គប្បីជាអ្នកអាចបដិបត្តិដើម្បីចាក់ធ្លុះរហូតដល់សច្ចៈ ករណីយកិច្ចដែលគួរធ្វើណានីមួយ មិនថាខ្ពស់ ឬទាបរបស់សព្រហ្មចារី ក្នុងការបរិកម្ម កសិណ សមាទានវត្តជាដើម និងការជួសជុលឱ្យល្អឡើងវិញនូវបាត្រចីវរជាដើមរបស់ខ្លួន ក៏គប្បីអង់អាច គប្បីឧស្សាហ៍ មិនខ្ជិលច្រអូស ប្រាជ្ញាក្នុង

ករណីយកិច្ចទាំងនោះ និងក្នុងកិច្ចដូចនោះយ៉ាងដទៃក៏ដូចគ្នា ។ សូម្បីកាលជាអ្នកអង់អាច ក៏គប្បីជាអ្នកត្រង់ដោយការប្រកបនូវបធានិយង្គទី ៣ ។ សូម្បីកាលជាអ្នកត្រង់ ក៏គប្បីជាអ្នកត្រង់ដោយល្អ ដោយជាអ្នកត្រង់គ្រាតែមួយ ឬដោយជាអ្នកត្រង់ក្នុងវេលាទៅកម្មោះ ដោយមិនដល់នូវការសរេគ្គាស តែធ្វើមិនឱ្យស្រោលធ្វើឱ្យរឿយៗ រហូតដល់អស់ជីវិត ឬថា ឈ្មោះថា ត្រង់(ឧជុ) ព្រោះធ្វើដោយការមិនអួតអាងថា ល្អ ឈ្មោះថា ត្រង់ដោយល្អ (សុហុជុ) ព្រោះមិនមានមាយា ។ ឬថា ឈ្មោះថា ត្រង់ ព្រោះលះភាពកោងនៃកាយ និងវាចា ឬថាត្រង់ដោយល្អព្រោះលះភាពកោងនៃចិត្ត ។ ឬឈ្មោះថា ត្រង់ ព្រោះមិនអួតនូវគុណដែលមិនមាន ។ ឈ្មោះថា ត្រង់ដោយល្អ ព្រោះមិនអត់ទ្រាំចំពោះលាភ ដែលកើតឡើងដោយគុណដែលមានមិន ។ ឈ្មោះថាជាអ្នកត្រង់ និងត្រង់ដោយល្អ ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខា ២-៣ ខាងដើម និងដោយបយោគសុទ្ធិ និងអាសយសុទ្ធិដោយប្រការដូច្នេះ ។

ភិក្ខុមិនត្រឹមតែជាអ្នកត្រង់ និងត្រង់ដោយល្អប៉ុណ្ណោះទេ ថែមទាំងជាអ្នកប្រដៅងាយទៀតផង ។ ក៏បុគ្គលណាត្រូវលោកពោលថា លោកមិនគួរធ្វើសេចក្តីនេះ ក៏ពោលថា លោកឃើញអ្វី លោកបានឮយ៉ាងណា លោកជាអ្វីជាមួយនឹង

យើង ទើបពោលតបយ៉ាងនេះថា ជាឧបជ្ឈាយ៍ អាចារ្យ មិត្តឃើញគ្នាម្តងម្កាលឬ ឬមិត្រជិតស្និទ្ធ រមែងបៀតបៀនអ្នកដោយកុំឱ្យនិយាយ ឬមិនព្រមទទួលធ្វើយ៉ាងនោះ អ្នកនោះឈ្មោះថា នៅឆ្ងាយចាកការចាក់ធ្លុះគុណវិសេស ។ ចំណែកអ្នកណាត្រូវលោកឱ្យឱវាទ ក៏ពោលថា ប្រពៃហើយ លោកម្ចាស់ លោកពោលល្អហើយ ។ ឈ្មោះថា ទោសរបស់ខ្លួនជារបស់ គឺខ្លួនឃើញបានលំបាក លោកឃើញខ្ញុំមានសភាពយ៉ាងនោះ អាស្រ័យមេត្តាសូមពោលទៀតចុះ ខ្ញុំមិនបានទទួលឱវាទអំពីសម្នាក់របស់លោកយូរណាស់មកហើយ និងបដិបត្តិតាមដែលលោកបង្រៀន បុគ្គលនោះឈ្មោះថា នៅជិតការចាក់ធ្លុះគុណវិសេស ព្រោះដូច្នោះបុគ្គលទទួលពាក្យរបស់អ្នកដទៃហើយធ្វើយ៉ាងនេះ ឈ្មោះថា ជាបុគ្គលអ្នកប្រដៅងាយ ។

មួយទៀត ជាអ្នកប្រដៅងាយយ៉ាងណា ក៏គប្បីជាអ្នកទន់ភ្លន់ក៏យ៉ាងនោះដែរ ។ បទថា **មុទុ** សេចក្តីថា ភិក្ខុត្រូវពួកគ្រហស្ថប្រើក្នុងការជាទូត ទៅទទួលបញ្ជូនសារជាដើម ក៏មិនធ្វើការទន់ជ្រាយក្នុងកិច្ចនោះ ជាអ្នកមាំទាំ គប្បីជាអ្នកទន់ភ្លន់ក្នុងវត្តបដិបត្តិ និងព្រហ្មចារ្យទាំងអស់ ការមិនត្រូវទទួលប្រើក្នុងកិច្ចនោះដូចមាសដែលជាងតុបតែងដោយល្អ ។ មួយ៉ាងទៀត បទថា **មុទុ** បានដល់

ជាអ្នកមិនមានមុខចង់ចិញ្ចើម គឺជាអ្នកមានមុខរីករាយ ចរចាតែពាក្យដែលឱ្យកើតតែសេចក្តីសុខ ប្រៀបដូចកំពង់ទឹកល្អហើយងាយស្រួលចុះ ។ មិនត្រឹមតែជាអ្នកទន់ភ្លន់ប៉ុណ្ណោះទេ គប្បីជាអ្នកមិនមានអតិមានះផង ។ មិនគប្បីមើលងាយអ្នកដទៃ ដោយវត្ថុនៃការមើលងាយមានជាតិ និងគោត្រជាដើម គប្បីជាអ្នកមានចិត្តស្មើដោយក្នុងចណ្ឌាល ដូចព្រះសារីបុត្តត្ថេរដូច្នេះ ។

## ទុតិយាគាថាវណ្ណនា

## ពណ៌នាគាថាទី ២

ព្រះដ៏មានព្រះភាគត្រាស់ត្រាស់ករណីយកិច្ច ដោយចំណែកមួយរបស់ភិក្ខុអ្នកទៅព្រៃ ដែលបំណងនូវការចាក់ធ្លុះសន្តិបទ ឬបដិបត្តិដើម្បីចាក់ធ្លុះសន្តិបទនោះយ៉ាងនោះហើយ មានពុទ្ធបំណងនឹងត្រាស់បន្តទៅទៀត ទើបត្រាស់គាថាទី ២ ថា សន្តុស្សកោ ច ជាដើម ។ ក្នុងគាថាទី ២ នោះ ភិក្ខុឈ្មោះថា សន្តោស ព្រោះសន្តោស ដោយសន្តោស ១២ យ៉ាង មានប្រការដូចពោលទុក ហើយក្នុងមង្គល-សូត្រនោះថា សន្តុដ្ឋី ច កតញ្ញុតា នេះ ។ ន័យម្យ៉ាងទៀត ភិក្ខុណា រមែងត្រេកអរ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **តុស្សកៈ** អ្នកត្រេកអរ ភិក្ខុ អ្នកត្រេកអរដោយរបស់ខ្លួនឯង អ្នកត្រេកអរនូវរបស់ដែលមាន អ្នកត្រេកអរដោយរបស់

ស្មើ ហេតុនោះ ទើបឈ្មោះថា **សន្តុស្សកៈ** អ្នកសន្តោស ។ បណ្តាលក្ខណៈ ៣ យ៉ាងនោះ បច្ច័យ ៤ ដែលលោកសម្តែងក្នុងពេលឧបសម្បទាយ៉ាង នេះថា បិណ្ឌិយាលោបភោជនំ និស្សាយ អាស្រ័យភោជន គឺបាយដែលរកមក ដោយស្មងជើងជាដើម និងខ្លួនទទួលទុកហើយ ឈ្មោះថា របស់ខ្លួន ។ ភិក្ខុមិន សម្តែងអាការៈខុសប្រក្រតីក្នុងវេលាទទួល និងវេលាបរិភោគ ញុំាងអត្តភាពឱ្យ ប្រព្រឹត្តទៅ ដោយបច្ច័យរបស់ខ្លួនល្អក្តី មិនល្អក្តី ដែលគេប្រគេនដោយគោរពក្តី ហៅថា អ្នកត្រេកអរដោយរបស់ខ្លួន ។ របស់ណាបានមកហើយ មានដល់ខ្លួន របស់នោះឈ្មោះថា មាននៅ ។ ភិក្ខុត្រេកអរដោយរបស់មាននោះទុំះឯង មិន ប្រាថ្នារបស់ក្រៅអំពីនោះ លះភាពជាអ្នកប្រាថ្នាកើនចំណែក (លាភច្រើន) ហៅថា អ្នកត្រេកអរដោយរបស់ដែលមាន ។ ការលះសេចក្តីត្រេកអរ មិនពេញចិត្តក្នុង ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ស្មើ ។ ភិក្ខុត្រេកអរក្នុងអារម្មណ៍ទាំងពួង ដោយអាការៈស្មើនោះ ហៅថា អ្នកត្រេកអរដោយអាការៈស្មើ ។

ឈ្មោះថា សុភរៈ ព្រោះគេចិញ្ចឹមដោយងាយ ។ លោកអធិប្បាយថា អ្នក ដែលគេចិញ្ចឹមងាយ ។ ភិក្ខុណា កាលមនុស្ស បានយកបាត្រដាក់បាយ ស្រូវ-សាលី និងដុំសាច់ឱ្យពេញប្រគេនហើយ សម្តែងភាវៈជាអ្នកមានមុខស្ងូក និង

ខូចចិត្តហើយមើលងាយនូវបិណ្ឌបាតនោះ ចំពោះមុខផងទាំងនោះដោយពាក្យថា "ពួកលោកឱ្យអ្វី?" គឺឱ្យដល់សាមណេរ និងគ្រហស្ថទាំងឡាយ ភិក្ខុនោះ ឈ្មោះថា ***ទុត្តរៈ*** (អ្នកដែលគេប្រដៅលំបាក) ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ ក៏គេចចេញអំពីចម្ងាយភ្លាមៗដោយពោលថា ភិក្ខុចិញ្ចឹមលំបាក នរណាក៏មិនអាចចិញ្ចឹមលោកបាន ។ ចំណែកភិក្ខុណា បានរបស់ក្រខ្វក់ ឬប្រណីត តិចឬច្រើន មានចិត្តល្អ មុខមាត់ស្រស់ថ្លាញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ភិក្ខុនោះ ឈ្មោះថា ***សុភរៈ*** (អ្នកដែលគេចិញ្ចឹមបានដោយងាយ)។ មនុស្សទាំងឡាយ ឃើញភិក្ខុនោះ ជាអ្នកស្និទ្ធស្នាល ក៏ប្តេជ្ញាទទួលចិញ្ចឹមថា ព្រះគុណម្ចាស់របស់យើងចិញ្ចឹមងាយ រមែងត្រេកអររបស់បន្តិចបន្តួច យើងទាំងឡាយនឹងចិញ្ចឹមលោក ។ ភិក្ខុបែបនេះ លោកបំណងថាជា ***សុភរៈ*** អ្នកចិញ្ចឹមបានដោយងាយក្នុងទីនេះ ។

កិច្ចរបស់ភិក្ខុនោះតិច ហេតុនោះ ភិក្ខុនោះឈ្មោះថា **អប្បកិច្ចៈ** អ្នកមានកិច្ចតិច មិនមែនអ្នកខ្វល់ខ្វាយដោយកិច្ចច្រើនយ៉ាង ដូចជាសប្បាយ និងការងារសប្បាយ និងជជែកគ្នា សប្បាយសេពគប់ស្និទ្ធស្នាលជាដើម ម្យ៉ាងទៀត ជាអ្នកវៀរកិច្ច មានការងារកសាង ការប្រៀនប្រដៅសាមណេរ និងអារាមិកជនទូទាំងវត្ត ។ លោកអធិប្បាយថា ការកោរសក់បួស កាត់ក្រចក ដាក់ស្បោកបាត្រ ជួសជុលចីវរជាដើមរបស់ខ្លួន ។ ក្រៅអំពីកិច្ចនោះ គឺធ្វើសមណធម៌ ។

ការប្រព្រឹត្តរបស់ភិក្ខុនោះស្រាល ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **សល្លហុកវុត្តិ** អ្នកមានការប្រព្រឹត្តស្រាល ។ ភិក្ខុអ្នកមានបរិក្ខារច្រើនរូបខ្លះ វេលាចេញដើរផ្លូវក៏ឱ្យមហាជនលើកបាត្រ ចីវរ គ្រឿងក្រាល ប្រេង ទឹកអំពៅជាដើមដ៏ច្រើនទូល កណ្តៀតជាដើម យ៉ាងណា ភិក្ខុណាមិនមានសភាពដូច្នោះ រមែងជាអ្នកមានបរិក្ខារតិច រក្សាត្រឹមតែសមណបរិក្ខារ ៨ មានបាត្រចីវរជាដើម[១]ប៉ុណ្ណោះ វេលាដើរផ្លូវ ក៏ដើរទៅដូចបក្សាមានតែស្លាប ភិក្ខុបែបនោះ លោកបំណងថា ជាអ្នកមានការប្រព្រឹត្តស្រាលក្នុងទីនេះ ។ ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុនោះស្ងប់ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា អ្នកមានឥន្ទ្រិយស្ងប់ ។ លោកអធិប្បាយថា អ្នកមានឥន្ទ្រិយមិនរាយមាយ ដោយអំណាចរាគៈជាដើមក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា **និបកោ** បានដល់ អ្នកជាវិញ្ញូជន គឺដឹងច្បាស់ បានដល់ អ្នកមានបញ្ញា អធិប្បាយថា អ្នកប្រកបដោយបញ្ញាជាគ្រឿងតាមរក្សាសីល ដោយបញ្ញាកំណត់បច្ច័យ ៤ មាន

---

១-អដ្ឋបរិក្ខាររបស់សមណៈ មាន ប្រាំបី គឺ សង្ឃាដិ ឧត្តរាសង្គ(ចីពរ) អន្តរវាសក (ស្បង់) កាយពន្ធនៈ(វត្ថពន្ធចង្កេះ) បាត្រ (ព្រមទាំងស្បោក និងយោគផង) កាំបិតកោរ (ព្រមទាំងថ្មសំលៀងផង) ម្ជុល(ព្រមទាំងបំពង់ម្ជុល និងចេសផង) តម្រងទឹក (ទាំងគូ និងសំពត់សម្រាប់ត្រងផង) ។

ចីវរជាដើម និងដោយបញ្ញាជាគ្រឿងដឹងនូវសប្បាយ ៧ យ៉ាង[១] មានអាវាសសប្បាយជាដើម ។

អ្នកមិនធ្វើឫក ហេតុនោះឈ្មោះថា **អប្បគព្ភៈ** អ្នកមិនធ្វើឫក អធិប្បាយថា វៀរចាកការធ្វើឫកតាមផ្លូវកាយ ៨ ហ៊ុន ចាកការធ្វើឫកតាមវាចា ៤ ហ៊ុននិងចាកការធ្វើឫកផ្លូវចិត្តច្រើនហ៊ុន ។

ការធ្វើមិនសមគួរតាមកាយ ក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ងូតទឹក ផ្លូវបិណ្ឌបាត និងការចូលកាន់បរិវេណជិតៗភូមិ ឈ្មោះថា ការធ្វើឫកតាមកាយ ៨ ហ៊ុន ។ មានយ៉ាងនេះថា ភិក្ខុរូបខ្លះក្នុងសាសនានេះអង្គុយត្រដោមក្បាលជង្គង់ ឬយកជើងដាក់ជើងក្នុងកណ្តាលសង្ឃ ។ ក្នុងកណ្តាលគណៈ ក្នុងទីប្រជុំបរិស័ទទាំង ៤ ក៏ដូចគ្នា ក្នុងបុគ្គលអ្នកចាស់ជាងក៏ដូចគ្នា ។ ចំណែកក្នុងរោងឆាន់ ភិក្ខុមិនឱ្យអាសនៈដល់អ្នកមានវស្សាច្រើនជាង ហាមអាសនៈដល់ភិក្ខុថ្មីក្នុងរោងភ្លើងក៏ដូចគ្នា ។ ក៏ក្នុងរោងភ្លើងនោះ ភិក្ខុមិនសូមឱកាសដល់ភិក្ខុអ្នក

---

១-វិសុទ្ធិមគ្គ ភាគ ១ ទំព័រ ២៤៩ លោកសម្តែងថា សប្បាយ ៧ យ៉ាងគឺ អាវាសសប្បាយ ១ គោចរសប្បាយ ១ កថាជាគ្រឿងពោលសប្បាយ ១ បុគ្គលសប្បាយ ១ ភោជនសប្បាយ ១ ឧតុសប្បាយ ១ ឥរិយាបថសប្បាយ ១ ។

មានវស្សាច្រើនជាង ធ្វើការបង្អាត់ភ្លើងជាដើម ។ ចំណែកកំពង់ងូតទឹក លោកពោលនេះថា មិនត្រូវប្រកាន់ថា មានវស្សាចាស់ជាង ឬខ្ចីជាង គប្បីងូតទឹកតាមលំដាប់អ្នកមកដល់ ភិក្ខុមិនអើពើពាក្យនោះ មកក្រោយក៏ចុះទឹក បៀតបៀនភិក្ខុចាស់ ឬភិក្ខុថ្មី ។ ចំណែកផ្លូវបិណ្ឌបាត ភិក្ខុទៅខាងមុខៗ យកដៃប៉ះដៃភិក្ខុអ្នកមានវស្សាច្រើនជាង ដើម្បីបំណាំងអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ និងអាហារដ៏ប្រសើរ ។ ក្នុងការចូលទៅកាន់បរិវេណជិតៗភូមិ ក៏មានជាដើមយ៉ាងនេះថា ភិក្ខុចូលទៅមុខភិក្ខុអ្នកមានវស្សាចាស់ជាង ធ្វើការលេងផ្លូវកាយជាមួយភិក្ខុកម្លោះនោះ ។

ការបន្ទឹកវាចាមិនសមគួរ ក្នុងសង្ឃ គណៈ បុគ្គល និងបរិវេណជិតៗ ឈ្មោះថា ធ្វើឫកតាមវាចា ៤ ហាន គឺជាដើមយ៉ាងនេះថា ភិក្ខុរូបខ្លះក្នុងសាសនានេះ មិនសូមឱកាសក្នុងកណ្តាលសង្ឃពោលធម៌ ។ ក្នុងគណៈ ក្នុងបុគ្គលអ្នកចាស់ជាងដូចដែលពោលមកមុនហើយដូចគ្នា ។ ក្នុងទីនេះ ភិក្ខុត្រូវមនុស្សទាំងឡាយ សួរបញ្ហា មិនសូមឱកាសភិក្ខុអ្នកមានវស្សាចាស់ជាងក៏ឆ្លើយបញ្ហា ។ ចំណែកក្នុងបរិវេណជិតៗស្រុក ភិក្ខុពោលជាដើមយ៉ាងនេះថា មានអ្វីក្នុងស្រុកនោះ បបរ ឬរបស់គួរ ទំពាស៊ី លោកនឹងឱ្យអ្វីដល់យើង ថ្ងៃនេះយើង ទំពាស៊ីអ្វី បរិភោគអ្វី និងផឹកអ្វី ។

សម្បីមិនដល់សេចក្តីល្មើសតាមផ្លូវកាយវាចា ក្នុងហានទុំះ ៗ តែក៏មាន

វិតក្កៈដែលមិនសមគួរប្រការផ្សេងៗ មានកាមវិតក្កៈជាដើម តាមផ្លូវចិត្តឈ្មោះថា ការធ្វើឫក តាមផ្លូវចិត្តមានច្រើនយ៉ាង ។

បទ កុលេសុ អននុគិទ្ធោ សេចក្តីថា ភិក្ខុចូលទៅរកត្រកូលទាំងនោះ មិនដោយសេចក្តីប្រាថ្នាបានបច្ច័យ ឬដោយការសេពគប់ស្និទ្ធស្នាល ដែលមិនសមគួរក្នុងត្រកូលទាំងនោះ លោកអធិប្បាយថា មិនសោកសៅរួមគ្នា មិនរីករាយរួមគ្នា មិនសុខផង កាលត្រកូលទាំងនោះប្រកបសុខ មិនប្រកបទុក្ខផង កាលត្រកូលទាំងនោះប្រកបទុក្ខ ឬកាលករណីយកិច្ចទាំងឡាយកើតឡើង ក៏មិនចូលប្រកបដោយខ្លួនឯង ។ ក៏បទថា អស្ស ដែលត្រាស់ទុកក្នុងបទថា សុវចោ អស្ស នៃគាថានេះ គប្បីប្រកបចូលជាមួយបទយ៉ាងនេះថា សន្តុស្សកោ ច អស្ស សុភរោ ច អស្ស ។

## តតិយគាថាវណ្ណនា

## ពណ៌នាគាថាទី ៣

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលត្រាស់ប្រាប់ករណីយកិច្ច សូម្បីលើសនោះ ដោយចំពោះយ៉ាងច្រើនដល់ភិក្ខុអ្នកទៅព្រៃ ដែលបំណងទីងចាក់ធ្លុះសន្តិបទហើយទៅ ឬបំណងទីងបដិបត្តិដើម្បីចាក់ធ្លុះសន្តិបទនោះយ៉ាងនេះហើយ ឥឡូវ

នេះ មានព្រះបំណងនឹងត្រាស់ប្រាប់អករណីយៈ ទើបត្រាស់កន្លះគាថាយ៉ាងនេះថា

**ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។**

កន្លះគាថានោះ មានសេចក្តីដូច្នេះ ភិក្ខុកាលធ្វើករណីយកិច្ចយ៉ាងនេះ ក៏មិនគប្បីប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ដែលហៅថា **ខុទ្ទៈ** គឺកាលមិនប្រព្រឹត្តដ៏លាមក មិនមែនមិនប្រព្រឹត្តតែកម្មអាក្រក់តែម្យ៉ាង សូម្បីកម្មតិចតួចអ្វី ៗ ក៏មិនប្រព្រឹត្ត លោកអធិប្បាយថា មិនប្រព្រឹត្តកម្មលាមក ទាំងចំនួនតិច ទាំងចំនួនច្រើន ។

អំពីនោះ ព្រះមានព្រះភាគទ្រង់សម្តែង ទោសដែលឃើញបានដោយខ្លួនឯង ក្នុងការប្រព្រឹត្តកម្មដ៏លាមកនោះថា យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។ ក៏ក្នុងពាក្យនេះព្រោះហេតុដែលអ្នកមិនមែនជាវិញ្ញូជនពួកដទៃ មិនយកជាប្រមាណ ។ ព្រោះវិញ្ញូជនពួកនោះនៅធ្វើ កម្មមិនមានទោស ឬមានទោស មានទោសតិច ឬទោសច្រើន ។ ចំណែកវិញ្ញូជនទាំងឡាយប៉ុណ្ណោះ កាន់ជាប្រមាណបាន ។ ព្រោះថា វិញ្ញូជនទាំងនោះ គិតសញ្ជឹងសាឡើងវិញហើយ រមែងតិះដៀលអ្នកដែលគួរតិះដៀល សរសើរអ្នកដែលគួរសរសើរ ។ ដូច្នោះ ទើបត្រាស់ថា វិញ្ញូ បរេ ។

ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ឧបចារៈនៃកម្មដ្ឋានផ្សេង ដោយករណីយកិច្ច និងអករណីយកិច្ច ដោយចំពោះតែម្យ៉ាងដល់ភិក្ខុអ្នកទៅព្រៃ ដែលបំណងនឹងចាក់ផ្ទះសន្តិបទហើយ ឬបំណងបដិបត្តិដើម្បីចាក់ផ្ទះសន្តិបទនោះ និងដល់ពួកភិក្ខុអ្នកបំណងនឹងទទួលយកកម្មដ្ឋានសូម្បីគ្រប់រូប ដោយលើកភិក្ខុអ្នកទៅព្រៃជាសម្គាល់ ដោយពីរគាថាកន្លះយ៉ាងនេះហើយ ឥឡូវនេះទើបទ្រង់ផ្ដើមត្រាស់មេត្តាកថា ដោយន័យថា សុខិនោ វា ខេមិនោ ហោន្តុ ជាដើម ដើម្បីជាព្រះបរិត្តកម្ចាត់ភ័យអំពីទេវតានោះ និងដើម្បីជាកម្មដ្ឋាន ដោយមានឈានជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។

បណ្ដាបទទាំងនោះ បទថា **សុខិនោ** បានដល់ អ្នកដល់ព្រមដោយសុខ ។ បទថា ខេមិនោ ប្រែថា អ្នកមានសេចក្ដីក្សេម ។ លោកអធិប្បាយថា អ្នកមិនមានភ័យ មិនមានឧបទ្រវៈ ។ បទថា សព្វេ បានដល់ មិនសេសសល់ ។ បទថា **សត្តា** បានដល់ សត្វមានជីវិត ។ បទថា **សុខិតត្តា** បានដល់ អ្នកមានចិត្តជាសុខ ។ ក៏ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា អ្នកមានសេចក្ដីសុខ គឺសុខផ្លូវកាយ ។ ឈ្មោះថា មានចិត្តជាសុខ គឺសេចក្ដីសុខផ្លូវចិត្ត ។ ឈ្មោះថា មានសេចក្ដីក្សេម សូម្បីដោយសុខទាំងពីរនោះ ឬដោយការទៅប្រាសចាកភ័យ និង

ឧបទ្រវៈទាំងពួង ។ ក៏ហេតុអ្វី ទើបទ្រង់ត្រាស់យ៉ាងនេះ ។ ដើម្បីសម្តែងអាការៈនៃមេត្តាភាវនា ។ ក៏កាលជាយ៉ាងនេះ ទើបគួរនឹង ចម្រើនមេត្តាថា សូមសត្វទាំងពួង ចូរមានសេចក្តីសុខដូច្នេះចុះ ចូរមានសេចក្តីក្សេមដូច្នេះចុះ ចូរជាអ្នកមានខ្លួនដល់សេចក្តីសុខដូច្នេះចុះ ។

## ចតុត្ថគាថាវណ្ណនា

**ពណ៌នាគាថា ទី ៤**

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងមេត្តាភាវនា ដោយសង្ខេបតាំងពីឧបចារៈដល់អប្បនាជាទីបំផុតយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងមេត្តាភាវនានោះ សូម្បីដោយពិស្តារ ទើបទ្រង់ត្រាស់ ២ គាថាថា យេ កេចិ ជាដើម ។ ន័យម្យ៉ាងទៀត ព្រោះចិត្តដែលសន្សំទៅក្នុងអារម្មណ៍ច្រើនៗ រមែងមិនឈប់ទៅក្នុងអារម្មណ៍តែមួយដោយគ្រាដំបូងប៉ុណ្ណោះ ដែលនឹងជាប់តាមអារម្មណ៍ដោយលំដាប់ដូច្នោះ ទើបត្រាស់ ២ គាថាថា **យេ កេចិ** ជាដើម ដើម្បីចិត្តដែលជាប់តាមទៅហើយឈប់ក្នុងអារម្មណ៍ដែលមានប្រភេទនៃទុកៈពួក ២ នៃសត្វ និងតិកៈពួក ៣ នៃសត្វមាន

តសថាវរទុកៈ[១]ជាដើម ។ ន័យម្យ៉ាងទៀត អារម្មណ៍ណា របស់អ្នកណា ជាអារម្មណ៍ ដែលប្រាកដច្បាស់ហើយ ចិត្តរបស់អ្នកនោះ រមែងតាំងនៅជាសុខក្នុងអារម្មណ៍នោះ ដូច្នោះអារម្មណ៍របស់ភិក្ខុរូបណា បណ្តាភិក្ខុទាំងនោះ ប្រាកដច្បាស់ហើយ ព្រះមានព្រះភាគជាម្ចាស់ មានព្រះពុទ្ធបំណងនឹងឱ្យចិត្តរបស់ភិក្ខុរូបនោះ តាំងនៅក្នុងអារម្មណ៍នោះ ទើបត្រាស់ ២ គាថាថា យេ កេចិ ជាដើម ដើម្បីបំភ្លឺសេចក្តីផ្សេងគ្នានៃអារម្មណ៍ជាទុកៈ និងតិកៈ មានតសថាវរទុកៈជាដើម ។

សេចក្តីពិតក្នុង ២ គាថានោះ ព្រះមានព្រះភាគទ្រង់សម្តែង ទុកៈពួក ២ មានសត្វ ៤ ទុកៈ គឺ **តសថាវរទុកៈ** (ពួក ២ នៃសត្វអ្នកតក់ស្លុត និងមាំមួន គឺមិនតក់ស្លុត) **ទិដ្ឋាទិដ្ឋទុកៈ** (ពួក ២ នៃសត្វដែលខ្លួនឃើញហើយ និងសត្វដែលខ្លួននៅមិនឃើញ) **ទូរសន្តិកទុកៈ** (ពួក ២ នៃសត្វនៅទីឆ្ងាយ និងអ្នកនៅទីជិត) ១ **ភូតសម្ភវេសីទុកៈ** (ពួក២ នៃសត្វអ្នកដែលកើតហើយ និងអ្នកដែលកំពុងស្វែងរកទីកើត) ១ ។ និងទ្រង់សម្តែងតិកៈ ពួក ៣ នៃសត្វ ៣ តិកៈ គឺ **ទីឃរស្ស–**

---

១-វគ្គិយ្យ តសថាវរេតិ តសា វុច្ចន្តិ សតណ្ហា ថាវរា និត្តណ្ហា ។ តេសំ វុត្តំ ហោតិ យោ និព្វានំ បាបុណាតិ សោ សត្តំ តសថាវរំ រក្ខិតុំ សមត្ថោ ហោតិ ។ បបញ្ចសូទនិយា មជ្ឈិមនិកាយដ្ឋកថាយ អង្គុលិមាលសុត្តវណ្ណនា ។

**មជ្ឈិមតិក:** (ពួក ៣ នៃសត្វ អ្នកមានអត្តភាពវែង ខាប និងកណ្តាល) ១ **មហន្តាណុកមជ្ឈិមតិក:**( ពួក ៣ នៃសត្វអ្នកមានអត្តភាពធំ តូច និង កណ្តាល) ១ **ថូលាណុកមជ្ឈិមតិក:** (ពួក ៣ នៃសត្វអ្នកមានអត្តភាព ធាត់ ស្គម និងកណ្តាល) ១ ដោយមជ្ឈិមបទជា ទីកើតប្រយោជន៍ក្នុង ៣ តិក: និង**អណុកថូលបទ**ជាទីកើតប្រយោជន៍ក្នុង ២ តិក: ដោយបទ ៦ បទមាន**ទីឃបទ**ជាដើម ។ បណ្តាបទទាំងនោះបទថា យេ កេចិ ជាពាក្យសម្តែងថាមិនមានចំណែកសេសសល់ឡើយ ។ ពួកសត្វដែលកើតហើយ ឈ្មោះថា **បាណភូត** ។ ន័យម្យ៉ាងទៀត សត្វទាំងឡាយរមែងដកដង្ហើម ហេតុនោះ ទើបឈ្មោះថា **បាណ:** ។ ទ្រង់កាន់យក**បញ្ចវោការសត្វ** ដែលអាស្រ័យដោយអស្សាសបស្សាស:(ខ្យល់ដកដង្ហើមចេញចូល) ដោយបទនេះ ។ សត្វទាំងឡាយ រមែងកើត ហេតុនោះ ទើបឈ្មោះថា **ភូត** ។ ទ្រង់កាន់យកឯកវោការសត្វ និង ចតុវោការសត្វដោយបទនេះ ។ បទថា អត្ថិ ប្រែថា មាន គឺមានព្រម ។

ព្រះមានព្រះភាគ ត្រាទ្រង់សម្តែងសត្វទាំងពួង ដែលទ្រង់សង្គ្រោះដោយទុក: និងតិក:រួមគ្នា ដោយបទថា **យេ កេចិ បាណភូតត្ថិ** នោះ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វទាំងនោះសូម្បីទាំងអស់ សម្តែងដោយទុក:នេះថា

តសា វា ថាវរា វា អនវសេសា ។

បណ្ដាបទទាំងនោះ សត្វទាំងឡាយរមែងតក់ស្លុត ហេតុនោះ ទើបឈ្មោះថា **តសា** ពាក្យនេះជាឈ្មោះរបស់សត្វទាំងឡាយ អ្នកមានតណ្ហា និងមានភ័យ ។ សត្វទាំងឡាយ រមែងមាំមួន ហេតុនោះ ទើបឈ្មោះថា ថាវរា ពាក្យនេះជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយ អ្នកលះតណ្ហា និងភ័យបានហើយ ។ ចំណែកសេសសល់របស់សត្វទាំងនោះមិនមាន ហេតុនោះ ទើបឈ្មោះថា អនវសេសា លោកអធិប្បាយថា សូម្បីគ្រប់សត្វ ។ ក៏ពាក្យណា ត្រាស់ទុកខាងចុងនៃគាថាទី ២ ពាក្យនោះ គប្បីភ្ជាប់ជាមួយគ្រប់ទុក: និងតិក: ។ បទថា **យេ កេចិ បាណភូតត្ថិ** សេចក្ដីថា សត្វទាំងឡាយតក់ស្លុតក្ដី មាំមួនក្ដី មិនសេសសល់ឡើយ សត្វទាំងនោះសូម្បីទាំងអស់ ចូរជាអ្នកមានខ្លួនដល់នូវសេចក្ដីសុខចុះ។ ពួកសត្វដែលកើតហើយក្ដី កំពុងស្វែងរកទីកើតក្ដីត្រឹមណា សត្វទាំងអស់សូម្បីទាំងនោះត្រឹមនោះ ចូរជាអ្នកមានខ្លួនដល់នូវសេចក្ដីសុខចុះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ បណ្ដាបទទាំង ៦ មាន **ទីឃា វា** ជាដើម ដែលសម្ដែងតិក: ៣ ពួក មាន***ទីឃរស្សមជ្ឈិមតិក:***ជាដើម ។ បទថា ទីឃា បានដល់ សត្វដែលមានអត្តភាពវែងមាន នាគ ត្រី ទន្សង ជាដើម ។ មែនពិត អត្តភាពរបស់នាគទាំងឡាយ

ក្នុងមហាសមុទ្រ សូម្បីមានទំហំច្រើនរយព្យាម ។ អត្តភាគរបស់ត្រី ទន្សង ជាដើម ក៏មានទំហំច្រើនយោជន៍ ។ បទថា មហន្តា បានដល់ សត្វមានអត្តភាពធំ ក្នុងទឹក មានត្រី អណ្តើកជាដើម នៅលើគោកមានស្តេចដំរីជាដើម ក្នុងពពួកអមនុស្ស ក៏ មានអសុរាជាដើម និងត្រាស់ថា រាហូជាកំពូលរបស់សត្វដែលមានអត្តភាពទាំងឡាយ ។ មែនពិត អត្តភាពរបស់រាហូនោះ មានកម្ពស់ ៤.៨០០ យោជន៍ ដៃប្រវែង ១.២០០ យោជន៍ ចន្លោះចិញ្ចើមម្ខាងទៅចិញ្ចើមម្ខាង ៥០ យោជន៍ ចន្លោះម្រាមដៃក៏ដូចគ្នា បាតដៃប្រវែង ២០០ យោជន៍ ។ បទថា មជ្ឈិមា បានដល់ អត្តភាពរបស់សេះ គោ ក្របី ជ្រូកជាដើម ។ បទថា រស្សកា បានដល់ សត្វទាំងឡាយមានទំហំទាប ត្រង់កណ្តាលវែង ត្រង់កណ្តាលធាត់ មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។ បទថា អណុក្កា បានដល់ សត្វទាំងឡាយដែលមានអត្តភាពល្អិត ឬតូចជាដើម ដែលកើតក្នុងទឹកជាដើម មិនមែនជាវិស័យរបស់មំសចក្ខុទេ ប៉ុន្តែជាវិស័យរបស់ ទិព្វចក្ខុ ។ ម្យ៉ាងទៀត សត្វពួកណាមានទំហំទាប ត្រង់កណ្តាលធំ និងត្រង់ កណ្តាលធាត់ ក្នុងជាតិនោះ ៗ សត្វទាំងនោះ គប្បីជ្រាបថា តូច ។ បទថា ថូលា បានដល់ សត្វទាំងឡាយ ដែលមានអត្តភាពមូលក្លំមាន ត្រី ខ្យងជាដើម ។

# បញ្ចមគាថាវណ្ណនា

## ពណ៌នាគាថា ទី ៥

ព្រះមានព្រះភាគ ទ្រង់សម្តែងសត្វទាំងឡាយ មិនឱ្យសេសសល់ដោយតិកៈយ៉ាងនេះហើយ ឥឡូវនេះទ្រង់សង្គ្រោះដោយទុកៈ ៣ ទុកៈថា ទិដ្ឋា វា យេ **ច អទិដ្ឋា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋា** បានដល់ សត្វពួកណា ដែលឃើញប្រាកដដោយភ្នែករបស់ខ្លួន ។ បទថា អទិដ្ឋា បានដល់ សត្វពួកណា តាំងនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាឡដទៃជាដើម ។ តែព្រះមានព្រះភាគ ទ្រង់សម្តែងសត្វដែលនៅឆ្ងាយ និងមិនឆ្ងាយអត្តភាពរបស់ខ្លួនដោយទុកៈនេះថា **យេ ច ទូរេ** វសន្តិ អវិទូរេ ។ សត្វទាំងនោះ គប្បីជ្រាប ដោយជាសត្វមិនមានជើង និងសត្វមានជើង ២ ។ ក៏ពួកសត្វដែលនៅក្នុងកាយរបស់ខ្លួន ហៅថា អវិទូរេ (នៅមិនឆ្ងាយ) ពួកសត្វនៅក្រៅកាយ ហៅថា **ទូរេ** (នៅឆ្ងាយ) ។ ម្យ៉ាងទៀត ពួកសត្វដែលនៅក្នុងឧបចារៈ ហៅថា នៅមិនឆ្ងាយ ។ ដែលនៅខាងក្រៅឧបចារៈ ហៅថា នៅឆ្ងាយ ។ សត្វដែលនៅក្នុងវិហារ តាមស្រុក ជនបទ ទ្វីប ចក្រវាឡ ហៅថា នៅក្នុងទីមិនឆ្ងាយ សត្វនៅក្នុងចក្រវាឡដទៃ ហៅថា នៅក្នុងទីឆ្ងាយ ។

បទថា ភូតា បានដល់ កើតហើយ ។ ព្រះខីណាស្រពអង្គណា កើតហើយ ទុំះឯង មិនរាប់ថានឹងកើតម្ដងទៀតទេ ពាក្យនោះជាឈ្មោះ របស់ព្រះខីណាស្រពអង្គនោះ ។ សត្វពួកណា ស្វែងរកទីកើត ហេតុនោះ សត្វទាំងនោះឈ្មោះ សម្ភវេសី ។ ពាក្យនេះជាឈ្មោះ របស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលកំពុងស្វែងរកទីកើត សូម្បីក្នុងអនាគត ព្រោះការសំយោជនៈនៅមិនទាន់លះ ។ ម្យ៉ាងទៀត បណ្ដាកំណើតទាំង ៤ ពួក សត្វដែលជាអណ្ឌជៈ (កើតក្នុងពង) និងជលាពុជៈ (កើតក្នុងគភ៌) នៅមិនទម្លាយសំបកពង និងស្រោមសុកចេញមកដរាបណា ក៏ឈ្មោះថា សម្ភវេសី ។ ដែលទម្លាយសំបកពង និងស្រោមសុកចេញហើយមកខាងក្រៅ ឈ្មោះថា **ភូត** ពួកសត្វដែលជាសំសេទជៈ និងឱបបាតិកៈឈ្មោះថា សម្ភវេសី ក្នុងខណៈបឋមចិត្ត តាំងតែខណៈទុតិយចិត្តទៅ ឈ្មោះថា **ភូត** ។ ម្យ៉ាងទៀត សត្វទាំងឡាយ កើតដោយឥរិយាបថណា នៅមិនប្ដូរឥរិយាបថទៅជាយ៉ាងដទៃទៅអំពីឥរិយាបថនោះ ដរាបណា ដរាបនោះ ឈ្មោះថា សម្ភវេសី ក្រៅអំពីនោះទៅ ឈ្មោះថា **ភូត** ។

## ឆដ្ឋគាថាវណ្ណនា

## ពណ៌នាគាថា ទី ៦

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងមេត្តាភាវនាក្នុងសត្វទាំងឡាយ ដោយប្រាថ្នាតែនឹងឱ្យចូលដល់ប្រយោជន៍សុខរបស់ភិក្ខុទាំងនោះ ដោយប្រការផ្សេងៗ

ដោយ ២ គាថា ថា **សុចិនោ វា** ជាដើម យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះ សូម្បីដោយប្រាថ្នាមិនឱ្យនូវវត្ថុដែលមិនជាប្រយោជន៍ និងសេចក្តីទុក្ខ ទើបត្រាស់ថា **ន បរោ បរំ និកុព្វេថ** ។ នេះជាបាឋៈចាស់ តែបច្ចុប្បន្ន សូត្រថា **បរំ ហិ** ដូច្នេះក៏ មាន បាឋៈនេះមិនល្អ ។

បណ្តាបទទាំងនោះ បទ **បរោ** បានដល់ ជនដទៃ ។ បទថា **បរំ** នូវជនដទៃ ។ បទថា **ន និកុព្វេថ** បានដល់ មិនកំហែងបៀតបៀន ។ បទថា **នាតិមញ្ញេថ** បានដល់ មិនគប្បីមើលងាយ ។ បទថា **កត្ថចិ** បានដល់ ក្នុងឱកាសណាមួយ គឺស្រុក គាមខេត្ត កណ្តាលញាតិ ឬកណ្តាលបុគ្គល ដូច្នេះជាដើម ។ បទថា **នំ** ប្រែថា នោះ ។ បទថា កិញ្ចិ បានដល់ អ្នកណាម្នាក់ គឺក្សត្រ ឬ ព្រាហ្មណ៍ គ្រហស្ថ ឬបព្វជិត ដែលដល់នូវសេចក្តីសុខ ឬសេចក្តីទុក្ខដូច្នេះជាដើម ។ បទថា ព្យារោសនា បដិឃសញ្ញា បានដល់ ព្រោះសេចក្តីក្រេវក្រោធដោយកាយវិការ និងវចីវិការ និងព្រោះចងគំនុំដោយមនោវិការ ។ ព្រោះកាលគួរនឹងត្រាស់ថា ព្យារោសនាយ បដិឃសញ្ញាយ តែក៏ត្រាស់ថា ព្យារោសនា បដិឃសញ្ញា ឬកាលគួរនឹងត្រាស់ថា សម្មទញ្ញាយ វិមុត្តា ក៏ត្រាស់ថា សម្មទញ្ញា វិមុត្តា និងដូចកាលគួរនឹងត្រាស់ថា អនុបុព្វសិក្ខាយ អនុបុព្វកិរិយាយ អនុបុព្វបដិបទាយ តែក៏ត្រាស់ថា អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា ដូច្នេះ ។ បទថា **នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នានូវសេចក្តី ទុក្ខដល់គ្នានឹង

គ្នា លោកអធិប្បាយទុកយ៉ាងណា? លោកអធិប្បាយទុកថា បុគ្គល មិនមែនត្រឹមតែចម្រើនមេត្តា ដោយធ្វើទុកក្នុងចិត្តជាដើមថា សូមសត្វទាំងឡាយ ចូរមានសេចក្តីសុខ មានសេចក្តីក្សេមប៉ុណ្ណោះទេ ប៉ុន្តែគប្បីធ្វើទុកក្នុងចិត្តយ៉ាងនេះ ថា និហ្នុំ បុគ្គលដទៃនរណា មិនគប្បីកំហែងបៀតបៀនបុគ្គលដទៃ មិនថានរណាៗ ដោយកិរិយាកោងរៀច មានបោកបញ្ឆោតជាដើម មិនគប្បីមើលងាយបុគ្គលដទៃ មិនថានរណាម្នាក់ មិនថាក្នុងប្រទេសណាមួយដោយវត្ថុនៃមានៈ ៩ យ៉ាង មាន ជាតិជាដើម និងមិនគប្បីប្រាថ្នាសេចក្តីទុក្ខដល់គ្នានឹងគ្នា ព្រោះសេចក្តីក្រេវក្រោធ ឬព្រោះការចងគំនុំ ដូច្នេះទៀតផង ។

## សត្តមគាថាវណ្ណនា

## **ពណ៌នាគាថា ទី ៧**

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអត្ថ ដោយប្រាថ្នាឱ្យគេចេញចាកវត្ថុមិនជាប្រយោជន៍ និងទុក្ខយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះនុ៎ះឯង ដោយឧបមាទើបត្រាស់ថា **មាតា យថា និយំ បុត្តំ** ជាដើម ។

គាថានោះមានសេចក្តីថា មាតាគប្បីរក្សាបុត្រក្នុងខ្លួន គឺបុត្រដែលកើតអំពីខ្លួន គប្បីបីបាច់ថែរក្សាបុត្រនោះ ដែលមានខ្លួនតែមួយប៉ុណ្ណោះដោយជីវិត គឺព្រមលះបង់សូម្បីជីវិតរបស់ខ្លួនថ្នាក់ថ្នមបុត្រនោះ ដើម្បីហាមការពារទុក្ខមកដល់បុត្រ

នោះ ថ្នមរក្សាបុត្រនោះយ៉ាងណា កុលបុត្រគប្បីចម្រើនមេត្តានេះឱ្យច្រើន គឺឱ្យកើតជារឿយៗ ឱ្យផ្សាយទៅ និងញ៉ាំងមេត្តាភាវនានោះឱ្យចម្រើន ដោយមានសត្វជាអារម្មណ៍មិនមានប្រមាណ ឬផ្សាយទៅមិនឱ្យសល់សូម្បីតែក្នុងសត្វមួយ ។

## អដ្ឋមគាថាវណ្ណនា

### ពណ៌នាគាថាទី ៨

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអាការៈទាំងពួងយ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនានោះទុំឯង ទើបត្រាស់ថា មេត្តញ្ច សព្វលោកស្មឹ ជាដើម ។

ក្នុងគាថានោះ ឈ្មោះថា មិត្ត ព្រោះស្រឡាញ់ និងរក្សា អធិប្បាយថា ព្រួយបារម្ភណ៍ ព្រោះមានអធ្យាស្រ័យក្នុងប្រយោជន៍ និងរក្សាឱ្យផុតចាកវត្ថុមិនជាប្រយោជន៍ ។ សភាពនៃមិត្តនោះ ឈ្មោះថា មេត្តា ។ បទថា សព្វលោកស្មឹ បានដល់ ក្នុងសត្វលោកមិនមានសេសសល់ឡើយ ។ មានក្នុងចិត្ត ហេតុនោះទើបឈ្មោះថា **មានសៈ** ។ ក៏ពាក្យថា **មានសៈ** នោះ លោកពោលយ៉ាងនេះ ព្រោះប្រកបជាមួយចិត្ត ។ បទថា ភាវយេ ប្រែថា ឱ្យចម្រើន ។ មិនមានប្រមាណ ហេតុនោះ ទើបឈ្មោះថា **អបរិមាណៈ** ។ លោកពោលយ៉ាងនេះ ក៏ព្រោះមេត្តា

មានសត្វ មិនមានប្រមាណជាអារម្មណ៍ ។ បទថា **ឧទ្ធំ** ប្រែថា ខាងលើ ។ ទ្រង់កាន់យកអរូបភពដោយបទនេះ ។ បទថា **អធោ** ប្រែថា ខាងក្រោម ។ ទ្រង់កាន់យកកាមភពដោយបទនេះ ។ បទថា **តិរិយំ** បានដល់ ទទឹង ។ ទ្រង់កាន់យករូប-ភពដោយបទនេះ ។ បទថា អសម្ពាធំ វៀរចាកសេចក្តីចង្អៀត ។ លោកអធិប្បាយថា មិនមានព្រំដែន ។ សត្រូវ លោកហៅថា ព្រំដែន អធិប្បាយថា ប្រព្រឹត្តទៅក្នុងទីមិនមានព្រំដែននោះ ។ បទថា **អវេរំ** បានដល់ វៀរចាកវេរ អធិប្បាយថា វៀរចាកសេចក្តីប្រាកដនៃចេតនាបង្កវេរ សូម្បីក្នុងចន្លោះៗ ។ បទថា អសបត្តំ បានដល់ប្រាសចាកសត្រូវ ។ មែនពិត បុគ្គលអ្នកនៅដោយមេត្តា រមែងជាទីស្រឡាញ់របស់មនុស្ស និងជាទីស្រឡាញ់របស់ពួកអមនុស្ស ។ សត្រូវ របស់គេរមែងមិនមាន ។ ព្រោះហេតុនោះ ការចាក់ទងក្នុងចិត្តរបស់គេនោះ លោកទើបពោលថា ***អសបត្តៈ*** ព្រោះប្រាសចាកសត្រូវ ។ ក៏ពាក្យដែលពោលថា សឹកសត្រូវៗ ជាពាក្យសម្រាប់បរិយាយ ។ ការពណ៌នា សេចក្តីតាមបទមានប៉ុណ្ណោះ ចំណែកការសម្តែងសេចក្តីដែលបំណាងក្នុងទីនេះមានដូច្នេះ ។

គប្បីចម្រើនផ្សាយមេត្តាដែលត្រាស់ទុកថា **ឯវម្បិ សព្វភូតេសុ មានសំ ភាវយេ អបរិមាណំ** ដូច្នេះ ផ្សាយមេត្តាមានទៅក្នុងចិត្តមិនមានប្រមាណ ឱ្យ

បន្ទះដល់សេចក្ដីចម្រើន រីកលូតលាស់ល្អចម្រើនក្នុងលោកទាំងមូល ។ តើផ្សាយមេត្តាចិត្តយ៉ាងណា គឺផ្សាយមេត្តានោះ ទៅមិនសល់ទាំងខាងលើ ខាងក្រោម ខាងទទឹង ខាងលើតាំងពីភវគ្គព្រហ្មចុះមក ខាងក្រោមតាំងតែអវចីនរកឡើងទៅ ខាងទទឹង បានដល់ទិសដ៏សេស ឬខាងលើ បានដល់ អរូបធាតុ ខាងក្រោម បានដល់ កាមធាតុ ខាងទទឹង បានដល់ រូបធាតុផ្សាយទៅមិនឱ្យសេសសល់ ។ ក៏ឯកាលចម្រើនមេត្តាទៅយ៉ាងនេះ ធ្វើមិនឱ្យមានសេចក្ដីតូចចង្អៀត ពៀរ និងសត្រូវ គប្បីចម្រើនមេត្តានោះ ដោយប្រការមិនចង្អៀត មិនមានពៀរ និងមិនមានសត្រូវ ។ ឬថាមេត្តានោះ បានដល់ ភាវនាសម្បទាជាគុណ ឈ្មោះថា មិនចង្អៀត ព្រោះជាឱកាសលោកទាំងមូល (គឺ៣ភូមិ) ជាគុណ ឈ្មោះថា មិនមានពៀរ ព្រោះកម្ចាត់ការចងអាឃាតរបស់ខ្លួនក្នុងសត្វដទៃទៀត ជាគុណ ឈ្មោះថា មិនមានសត្រូវ ព្រោះកម្ចាត់ការចងអាឃាតរបស់សត្វដទៃក្នុងខ្លួនទៀត ។ ក៏គប្បីចម្រើនមេត្តា ដែលមានក្នុងចិត្តនោះ ដែលមិនចង្អៀត ដែលមិនមានពៀរ ដែលមិនមានសត្រូវ មិនមានប្រមាណទៅក្នុងលោកទាំងមូល ដោយកំណត់ទិសទាំង ៣ គឺខាងលើ ខាងក្រោម និងខាងទទឹង ។

# នវមគាថាវណ្ណនា

## ពណ៌នាគាថា ទី ៩

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ កាលទ្រង់សម្តែងការមិនមានឥរិយាបថជាក់លាក់របស់អ្នកប្រកបរឿយៗ នៅការចម្រើនមេត្តានោះ ទើបត្រាស់ថា តិដ្ឋញ្ចរំ ។បេ។ អធិដ្ឋេយ្យ ដូច្នេះ ។

គាថានោះមានសេចក្តីថា អ្នកចម្រើនមេត្តាកាលចម្រើនមេត្តាមានក្នុងចិត្តនោះយ៉ាងនេះ មិនត្រូវកំណត់ឥរិយាបថ ដូចក្នុងព្រះបាលីថា អង្គុយសមាធិ តាំងកាយឱ្យត្រង់ដូច្នេះជាដើម កាលធ្វើឱ្យធូរស្រាល ដោយបន្ទោបង់ការឈឺចាប់អស់កម្លាំងដោយឥរិយាបថ យ៉ាងណាមួយ តាមសប្បាយ និងឈរ ឬដើរ អង្គុយ ឬដេក ត្រឹមណា ក៏គប្បីតាំងសតិក្នុងមេត្តាឈាននោះទុកត្រឹមនោះ ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងភាពជាអ្នកជំនាញ ទើបត្រាស់ថា តិដ្ឋញ្ចរំ ជាដើម ។ មែនពិត អ្នកជំនាញហើយ ញុំាងបំណងនឹងតាំងសតិក្នុងមេត្តាឈាន ដោយឥរិយាបថមានឈរ ឬដើរ និងអង្គុយ ឬដេកក៏បាន ។ ន័យម្យ៉ាងទៀត អ្នកជំនាញ នឹងឈរ ឬដើរ និងអង្គុយ ឬដេក ព្រោះហេតុនោះ

ការឈរជាដើម រមែងមិនធ្វើអន្តរាយដល់អ្នកនោះ ។ ម្យ៉ាងទៀត អ្នកជំនាញញ៉ាំងបំណង និងតាំងសតិនោះទុក ក្នុងមេត្តាឈាននេះត្រឹមណា ក៏ត្រូវជាអ្នកប្រាសចាកសេចក្តីងងុយដេក ទើបតាំងសតិទុកបានត្រឹមនោះ ។ សេចក្តីយឺតយូរក្នុងមេត្តាឈាននោះ របស់អ្នកនោះ រមែងមិនមាន ព្រោះហេតុនោះ ទើបត្រាស់ថា និងឈរ ឬដើរ អង្គុយ ឬដេក ទៅជាអ្នកប្រាសចាកសេចក្តីងងុយដេកត្រឹមណា ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

គាថានោះ មានអធិប្បាយដូច្នេះ អ្នកជំនាញគប្បីចម្រើនមេត្តា ដែលត្រាស់ទុកថា មេត្តញ្ច សព្វលោកស្មឹ មានសំ ភាវយេ ដោយប្រការដែលអ្នកជំនាញមិនអើពើដោយឥរិយាបថ បណ្តាឥរិយាបថមានឈរជាដើម ឬដល់ឥរិយាបថមានឈរជាដើម ញ៉ាំងបំណង និងតាំងសតិក្នុងមេត្តាឈាននោះត្រឹមណា ជាអ្នកប្រាសចាកសេចក្តីងងុយដេក ហើយក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងភាពជាអ្នកជំនាញ ក្នុងមេត្តាភាវនាយ៉ាងនេះ ទ្រង់ប្រកាសកិច្ចអ្នកប្រកបក្នុងមេត្តាវិហារធម៌ ការនៅដោយមេត្តានោះថា ឯតំ សតឹ អធិដ្ឋេយ្យ គប្បីតាំងសតិនោះទុក ឥឡូវនេះ កាលទ្រង់លើកសរសើរការនៅនោះ ទើបត្រាស់ថា **ព្រហ្មមេតំ វិហារំ ឥធមាហុ** ។

គាថានោះ មានសេចក្តីថា ការនៅដោយមេត្តានេះឯណា ទ្រង់សរសើរតាំងតែអំពីដើម មានព្រះពុទ្ធតម្រាស់ថា **សុខិនោ វា ខេមិនោ វា ហោន្តុ** ចូរជាអ្នកមានសេចក្តីសុខ ឬមានសេចក្តីក្សេម ហើយត្រាស់បន្ថែមទៀតថា **ឯតំ សតឹ អធិដ្ឋេយ្យ** គប្បីតាំងសតិនោះ អស់កាលត្រឹមនោះ ។ អ្នកប្រាជ្ញទាំងឡាយ ពោលការនៅនោះថា ***ព្រហ្មវិហារ*** គឺនៅដូចព្រហ្ម ពោលការនៅនោះថា ***សេដ្ឋវិហារ*** ការនៅយ៉ាងប្រសើរបំផុត ក្នុងព្រះសាសនា គឺក្នុងធម្មវិន័យរបស់ព្រះអរិយៈនេះ ព្រោះមិនមានទោសក្នុងការនៅ ៤ យ៉ាងគឺ នៅជាទិព្វ នៅដូចព្រហ្ម នៅដូចព្រះអរិយៈ និងនៅដោយឥរិយាបថ ឯការនៅដោយមេត្តានោះ ធ្វើប្រយោជន៍ដល់ខ្លួន និងដល់អ្នកដទៃ ។ ព្រោះហេតុ ដែលសេចក្តីស្ងប់ទាក់ទងគ្នាមិនត្រូវជ្រៀតជ្រែកដូច្នេះ អ្នកចម្រើនមេត្តា ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី នៅមិនងងុយដេក ត្រឹមណា ក៏គប្បីតាំងសតិនោះ ទុកត្រឹមនោះ ។

## ធសមគាថាវណ្ណនា

## ពណ៌នាគាថា ទី ១០

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងមេត្តាភាវនាប្រការផ្សេងៗដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុ ដែលមេត្តាជិត**អត្តទិដ្ឋិ**

(សេចក្តីឃើញថាជាខ្លួន) ព្រោះមានសត្វជាអារម្មណ៍ដូច្នោះ កាលទ្រង់សម្តែងចាក់ធ្លុះនូវអរិយភូមិ ធ្វើមេត្តាឈាននោះទុំះឯងឱ្យជាបាទដល់ភិក្ខុទាំងនោះ ដើម្បីហាមការប្រកាន់យកនូវទិដ្ឋិជាប្រមុខ ទើបទ្រង់បញ្ចប់ទេសនានេះថា **ទិដ្ឋិញ្ច អនុបគម្ម** ជាដើម ។

គាថានោះ មានសេចក្តីថា ការនៅដោយមេត្តាឈាននេះណា ទ្រង់សរសើរទុកថា **ព្រហ្មមេតំ វិហារំ ឥធមាហុ** អ្នកទាំងឡាយ ពោលការនៅនោះថា ព្រហ្មវិហារក្នុងធម្មវិន័យនេះ អ្នកចម្រើនចេញចាកទៅនៅដោយមេត្តាឈាននោះហើយ កំណត់(នាម)ធម៌មានវិតក្កវិចារៈជាដើម ហើយកំណត់រូបធម៌ និង ដោយការកំណត់នាមរូបនេះ ក៏មិនចាប់ទុកទិដ្ឋិយ៉ាងនេះថា នេះកងសង្ខារដ៏បរិសុទ្ធ បុគ្គលរមែងកាន់មិនបានថា សត្វក្នុងសង្ខារនេះដូច្នេះ ជាអ្នកមានសីលដោយលោកុត្តរសីល តាមលំដាប់ដល់ព្រមដោយទស្សនៈ ព្រោះសម្គាល់ថា សម្មាទិដ្ឋិ ក្នុងសោតាបត្តិមគ្គ ដែលប្រកបដោយលោកុត្តរសីល តអំពីនោះ ក៏នាំចេញកម្ចាត់រម្ងាប់សេចក្តីជំពាក់ចិត្តក្នុងកាមទាំងឡាយ គឺកិលេសកាមដែលលះមិនបាន ដោយការធ្វើឱ្យស្តួចស្តើងដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ និងការមិនឱ្យសល់ឡើយ ក៏រមែងមិនចូលដល់ការដេកក្នុងគភ៌មាតាទៀត គឺមិនត្រូវដេកក្នុងគភ៌

ទៀតយ៉ាងពិតប្រាកដ បានដល់ កើតក្នុងពពួកទេវតាក្នុងសុទ្ធាវាសទាំងឡាយ ចាក់ធ្លុះព្រះអរហត្តហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះនុ៎ះឯង ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បញ្ចប់ទេសនាយ៉ាងនេះ ហើយត្រាស់នឹងភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយទៅចុះ អ្នកទាំងឡាយ ចូលទៅដងព្រៃនោះនុ៎ះឯង នឹងចូរគោះគាំងក្នុងថ្ងៃធម្មសវនៈ(ថ្ងៃសន្ទនាធម៌) ទាំង ៨ ថ្ងៃ ក្នុង១ខែ ហើយចូរតាំងព្រះសូត្រនេះ ចូរធ្វើធម្មកថា ពោលធម៌សន្ទនាធម៌ អនុមោទនាគ្នា ចូរសេពគប់ ចូរចម្រើន ចូរធ្វើឱ្យច្រើននូវកម្មដ្ឋាននេះឯង ពួកអមនុស្សសូម្បីទាំងនោះ នឹងមិនសម្តែងអារម្មណ៍មិនជាទីភ័យខ្លាចនោះ នឹងប្រាថ្នាប្រយោជន៍ដល់ពួកលោកដោយពិត ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ថា សាធុ ដូច្នេះ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំហើយ ធ្វើប្រទក្សិណទៅកាន់ដងព្រៃនោះ ហើយធ្វើតាមដែលទ្រង់បង្រៀនគ្រប់ប្រការ ។ ទេវតាទាំងឡាយ កើតបីតិសោមនស្សថាព្រះគុណម្ចាស់ទាំងឡាយ ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីចម្រើនដល់ពួកយើង ។ ទេវតាទាំងនោះ ក៏នាំគ្នាប្រមូលសម្អាតសេនាសនៈផ្ទាល់ខ្លួន ដាក់បែងទឹកក្តៅ ច្របាច់ជើង គក់ខ្នង រៀបចំរក្សាទុក ភិក្ខុសូម្បីពួកនោះក៏នាំគ្នាចម្រើនមេត្តា ធ្វើមេត្តានោះឱ្យជាបាទ ផ្តើមវិបស្សនាក៏ចាក់ធ្លុះព្រះអរហត្តដែលជាផលដ៏ប្រសើរ

*ខាងក្នុងត្រីមាសនោះទុំឯងទាំងអស់អន្ត បវារណាដោយបរិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណាចេញវស្សា ។*

ឯវម្បិ អន្តកុសលេន តថាគតេន

**ធម្មិស្សរេន កថិតំ ករណីយមត្ថំ**

កត្វានុកុយ្យ បរមំ ហានយស្ស សន្តី

សន្តំ បទំ អភិសមេន្តិ សមត្តបញ្ញា។

**តស្មា ហិ តំ អមតមច្ចុតមរិយកន្តំ**

សន្តំ បទំ អភិសមេច្ចវិហារិតុកាមោ

វិញ្ញូ ជនោ វិមលសីលសមាធិបញ្ញាភេទំ

ករេយ្យ សតតំ ករណីយមត្ថន្តិ ។

***ព្រះតថាគតជាម្ចាស់នៃធម៌ ទ្រង់ឆ្លាតក្នុងប្រយោជន៍ ត្រាស់***

***ករណីយមេត្តសូត្រដែលមានប្រយោជន៍ ដោយប្រការដូច្នេះ ។***

***ភិក្ខុទាំងឡាយ អ្នកមានបញ្ញាបរិបូណ៌ បានធ្វើនូវសេចក្តី***

***ស្ងប់ នៃមហាភ័យដ៏ប្រសើរ ក៏ចាក់ធ្លុះសន្តិបទ ។***

***ព្រោះដូច្នោះឯង វិញ្ញូជនអ្នកបំណងនឹងចាក់ធ្លុះសន្តិបទ***

*ដែលជាអមតៈគួរអស្ចារ្យ ដែលព្រះអរិយៈជាម្ចាស់រក្សាហើយ ក៏គប្បីធ្វើករណីយដែលមានប្រយោជន៍ផ្សេងដោយសីល សមាធិ បញ្ញា គ្មានមន្ទិលអ្វីឡើយ ។*

បរមត្ថជោតិកាយ ខុទ្ទកបាឋដ្ឋកថាយ

មេត្តសុត្តវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថាមេត្តសូត្រ

នៃ

អដ្ឋកថា ខុទ្ទកបាឋៈ ឈ្មោះថា បរមត្ថជោតិកា ។